CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
## The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ ថ្ងៃទី០១-៣០ ខែមិថុនា ឆ្នាំ២០១៥ លក់តម្លៃ ១០០០រៀល

លេខ ៨៧

## ២០១៥! ពលរដ្ឋមើលឃើញបញ្ហាសំរាមនៅតែមិនរៀបរយ



### សេចក្ដីជូនដំណឹង

គណៈកម្មការសម្រាប់កិច្ចការមរណសាក្សីនៅកម្ពុជា សូមជម្រាបដល់បងប្អូនគ្រីស្តបរិស័ទទាំងអស់ ឲ្យបានជ្រាបថា បច្ចុប្បន្នគណៈកម្មការយើងខ្ញុំកំពុងធ្វើ និង ចងក្រងសំណុំឯកសារអំពីមរណសាក្សី នៃព្រះសហគមន៍កាតូលិក។ សូមបងប្អូនសហការផ្ដល់ជាព័ត៌មានមកកាន់ ៖ **លោក រឿង ឆ័ត្រសិរី** ( Fr. RoeungChatsirey )។ **Tel: 077 800 211 / 096 34 22 144**

អ៊ីម៉ែល ៖ martyrscambodia@gmail.com | ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ

# រូបភាពសង្គម



ព្រះសង្ឃ មន្ត្រីរាជការ និងប្រជាពលរដ្ឋចូលរួមព្រះរាជពិធីដង្ហែសញ្ញាបត្រព្រះគោរមងារ "ព្រះស្រីលោកធម្មិករាជ" ថ្វាយព្រះមហាក្សត្រ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី កាលពីថ្ងៃទី៣ មិថុនា ២០១៥។



យុវជនចូលរួមព្រឹត្តិការរត់ប្រណាំងពណ៌ ( Color Race ) ដែលរៀបចំដោយក្រុមហ៊ុន Metfone កាលពីថ្ងៃទី៣០ ឧសភា នៅកោះពេជ្រ។




ប្រជាពលរដ្ឋចូលរួមទិវារត់ប្រណាំងភ្នំពេញពាក់កណ្តាលម៉ារ៉ាតុនអន្តរជាតិលើកទី៥ ដើម្បីរកថវិកាជួយមន្ទីរពេទ្យគន្ធបុប្ផា និងទាក់ទាញទេសចរណ៍ កាលពីថ្ងៃទី៣១ ឧសភា ២០១៥។



កម្មករនេសាទខ្មែរដែលត្រូវបានជួញដូរកម្លាំងពលកម្មលើទូកនេសាទថៃនៅកោះឥណ្ឌូនេស៊ីត្រូវបានបញ្ជូនមកកម្ពុជា កាលពីថ្ងៃទី២ មិថុនា ២០១៥។



លោក Scott Busby ឧបការីរងរដ្ឋមន្ត្រីការបរទេសអាមេរិក ទទួលបន្ទុកផ្នែកប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងការងារ ជួបជាមួយលោក ហោ ណាំហុង និយាយអំពីច្បាប់ស្តីពីអង្គការ។

Radio Veritas Asia
Crossing Borders, Sharing Christ

**វិទ្យុវ៉ារីតាស់អាស៊ី ( RVA ) ផ្សាយតាមរលកធាតុអាកាសខ្លី ( SW )**
**ភាសាខ្មែររយៈពេល ៣០ នាទីរាល់ថ្ងៃ :**

ពីម៉ោង៥:០០-៥:៣០នាទីល្ងាច តាមរលកធាតុអាកាសខ្លី ១១៨៥០ គីឡូហឺតស៍ ត្រូវនឹងកម្ពស់ ២៥,៣២ ម៉ែត្រ។

ស្តាប់វិទ្យុវ៉ារីតាស់អាស៊ី ( RVA ) លោកអ្នកនឹងទទួលបានចំណេះដឹងទូទៅជាច្រើនទាក់ទងនឹង ជីវិតរស់នៅប្រចាំថ្ងៃ សង្គម និងព័ត៌មាននានាពីព្រះសហគមន៍កាតូលិកកម្ពុជា។

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក**

ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានី ភ្នំពេញ

**Tel/Fax** : (855) 23 224 120

**Email** : csccambodia@gmail.com / **Website** : www.catholiccambodia.org

**ចាងហ្វាង : លោក លី សុវណ្ណា**

Licence ៣៧០ ពម.ប្រក./ ២៤-មិថុនា-២០១០

# អំពើពុករលួយ នៅតែជាចំណោទរសើបសម្រាប់កម្ពុជា



*លោក លី សុវណ្ណា*
*ចាងហ្វាងកាសែតអ្នកនាំសារ*

ទោះបីកម្ពុជាបានបង្កើតច្បាប់និងអង្គភាពប្រឆាំងអំពើពុករលួយ ថ្នាក់ជាតិមួយ ដើម្បីបង្ក្រាបដល់ជនខិលខូចទាំងឡាយក៏ដោយ ក៏មិនទាន់មានអ្វីអាចផ្លាស់ប្តូរ ជាដុំកំភួនសម្រាប់ការប្រឆាំងអំពើពុករលួយ ឬលប់បំបាត់ កាត់បន្ថយ នូវអំពើពុករលួយក្នុងសង្គមកម្ពុជានេះដែរ។ ដោយសារ អំពើ ពុករលួយបានចាក់ឫសយ៉ាងជ្រៅទៅហើយ។

វាសឹងតែក្លាយ ទៅជាទម្លាប់របស់សង្គមមួយនេះ គឺនៅគ្រប់ស្រទាប់វណ្ណៈតែម្តង មិនថាស្ថាប័នរដ្ឋ ឬសង្គមស៊ីវិល ឬស្ថាប័នឯកជន ឬពលរដ្ឋធម្មតានោះទេ គឺសុទ្ធតែបានចូលរួមប្រព្រឹត្តអំពើពុករលួយ។ ដូចពាក្យកំប្លែងមួយ តែងនិយាយថា "ស៊ីតាមជំនាញ"។

ខ្ញុំសូមលើកយក តែករណីតូចតាចដែលបានកើតឡើង ក្នុងជីវភាពប្រចាំថ្ងៃមកបង្ហាញខ្លះៗទៅចុះ ។ ករណីផាកពិន័យ ត្រួតពិនិត្យសុវត្ថិភាពចរាចរណ៍ ការធ្វើលិខិតស្នាមផ្សេងៗ។ល។ សេវាទាំងអស់ ឬការផាកពិន័យទាំងឡាយ សុទ្ធមានតែចែងក្នុងច្បាប់។ ប៉ុន្តែជាក់ស្តែងមិនដូចគ្នាឡើយ ទាំងអ្នកអនុវត្តច្បាប់និងប្រជាពលរដ្ឋខ្លួនឯង សុខចិត្តទទួលផាកពិន័យ ដោយបង់ថ្លៃតិច មិនយកវិក័យបត្រ ឬបង់លុយជូនសមត្ថកិច្ចចរាចរណ៍ ដើម្បីអាចបិទភ្នែកសមត្ថកិច្ចករណីផ្ទុកលើសទម្ងន់ ជាដើម។សកម្មភាពទាំងនេះ មិនពិបាករកឡើយ គ្រាន់តែទៅឈរនៅតាម ផ្លូវកែងដែលមានភ្លើងសញ្ញាចរាចរណ៍ តាមមហាវិថីសហព័ន្ធរុស្ស៊ីឃើញហើយ។ សេវាកម្មមួយចំនួនក្នុងមូលដ្ឋាន គឺពលរដ្ឋអាចបង់សេវាបន្ថែម ដើម្បីទទួលបានលទ្ធផលឆាប់រហ័សសម្រាប់សេវា លើលិខិតស្នាមនានា។ល។ ការបង់នេះតែងតែលើសទៅនឹងតម្លៃដែលមានកំណត់ក្នុងច្បាប់។

មួយវិញទៀត ទៅទិញទំនិញនៅក្នុងផ្សារទូទៅ (មិនមែនផ្សារទំនើប) ពេលដែលសុំឲ្យមាន ការសរសេរវិក័យបត្រ តែងតែមានសំណួរត្រលប់មកវិញថា "ចង់ឲ្យខ្ញុំសរសេរដាក់តម្លៃប៉ុន្មាន?"។ នេះអាចបញ្ជាក់បានថា មានអ្នកធ្លាប់បង្កើតតម្លៃលើវិក័យបត្រទាំងអស់នេះ នៅពេលគេទិញទំនិញសម្រាប់ស្ថាប័នរដ្ឋ សង្គមស៊ីវិល ឬក្រុមហ៊ុនឯកជន។ល។

យើងបានដឹងហើយថា អំពើពុករលួយ នាំឲ្យមានការខាតបង់យ៉ាងច្រើនសន្ធឹកសន្ធាប់នូវថវិការជាតិ ឬក៏នាំឲ្យមានផលប៉ះពាល់ ដល់ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រក្នុងប្រទេសមួយនេះ។ ប្រមុខដឹកនាំកំពូលៗរបស់កម្ពុជា ក៏បានបង្ហាញឆន្ទៈក្នុងការប្រឆាំង ជនទាំងឡាយណា ដែលប្រព្រឹត្តអំពើពុករលួយនេះ។ ប៉ុន្តែសកម្មភាពអនុវត្តរបស់ថ្នាក់ក្រោម វាហាក់ដូចជានៅស្ទាក់ស្ទើរនៅឡើយ។ ពេលខ្លះត្រូវរង់ចាំឲ្យមានពាក្យបណ្តឹងសិន។ ការប្រព្រឹត្តជាក់ស្តែង ហើយបើគ្មានអ្នកប្តឹង គឺមិនចាត់ការទេ។

តើយើងទាំងអស់គ្នាគួរចូលរួមរបៀបណា? ឈរចាំរិះគន់នូវអំពើអសកម្ម របស់អ្នកប្រព្រឹត្តអំពើពុករលួយឬយ៉ាងណា?

ចម្លើយគឺ "ទេ"។ មិនគួរឈរចាំរិះគន់ទេ គឺពលរដ្ឋត្រូវចូលរួមយ៉ាងសកម្មទាំងអស់គ្នា ជាមួយអជ្ញាធរ ជាមួយសមត្ថកិច្ច គ្រប់ផ្នែកទាំងអស់ក្នុងការមិនប្រព្រឹត្តអំពុករលួយ។ ពាក្យមួយឃ្លានិយាយថា "ខ្មោចស្រុកមិនបើកដៃ ខ្មោចព្រៃមិនហ៊ានទេ" ។ ពិតណាស់ បើគ្មានអ្នកសូក ក៏គ្មានអ្នកដែលទទួលសំណូកដែរ។

ហេតុនេះ ខ្ញុំសូមលើកទឹកចិត្តបងប្អូនឲ្យចូលរួមទាំងអស់គ្នា ដោយចាប់ពីខ្លួនឯងផ្ទាល់តែម្តង។ ទាំងនេះវាជាតួនាទីរបស់យើងទាំងអស់គ្នា ជាពលរដ្ឋត្រូវចូលជាមួយអាជ្ញាធរ ដើម្បីអភិវឌ្ឍសង្គមយើង ឲ្យមានការរីកចម្រើនប្រសើរឡើង ដែលអាចកាត់បន្ថយ ការប្រព្រឹត្តអំពើពុករលួយជាអតិបរមា ៕

## ព័ត៌មានកាតូលិកអន្តរជាតិ

### សម្តេចប៉ាប ៖ ព្រះសហគមន៍គ្មានការបញ្ចុះបញ្ចូលទេ

តាមវិទ្យុវ៉ាទីកង់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានផ្តាំផ្ញើរទៅគ្រីស្តបរិស័ទទាំងអស់ថា ក្នុងព្រះសហគមន៍គួរតែស្វែងរកនូវភាពឯកភាពគ្នាមួយ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ លោកបានបញ្ជាក់ទៀតថា គំនិតឯកភាពគ្នានេះគឺមិនមែនកើតឡើងដោយការបញ្ចុះបញ្ចូល ឬការតស៊ូមតិណាមួយទេ គឺត្រូវតែកើតឡើងអំពីឆន្ទៈ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានបញ្ជាក់ថា រាល់ទស្សនៈ និងគោលគំនិតដែលចេញមកពីព្រះសហគមន៍ គឺដាច់ខាត គ្មានការកេងចំណេញផលប្រយោជន៍ គ្មានទំនាស់ គ្មានការអន្ទងពីនរណាម្នាក់ ប៉ុន្តែជាគោលគំនិត ដែលផុសចេញមកពីទឹកចិត្តដែលតម្រង់ផ្លូវ និងគោលដៅដោយព្រះជាម្ចាស់។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានធ្វើការផ្តែផ្តាំទៅគ្រប់ព្រះសហគមន៍ទាំងអស់ថា ក្នុងព្រះវិហារនិងគ្រប់មណ្ឌលសកម្មភាព គឺមានតែព្រះវិញ្ញាណបរិសុទ្ធមួយប៉ុណ្ណោះ ដែលអាចយាងចូលមនុស្សគ្រប់គ្នា នៅក្នុងព្រះសហគមន៍ ប៉ុន្តែព្រះសហគមន៍ដាច់ខាតគឺត្រូវតែគ្មានចលនានៅក្នុងនោះ៕

### សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ជំរុញឲ្យអាណាព្យាបាល ក្លាយជាអ្នកអប់រំ



Photo: Vannsambath

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ កាលពីពេលថ្មីៗនេះបានថ្លែងថា ឪពុកម្តាយគឺមានតួនាទីសំខាន់ណាស់ នៅក្នុងគ្រួសារ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ លោកបានអំពាវនាវ និងជំរុញឲ្យឪពុក និងម្តាយគិតគូឡើងវិញ នូវតួនាទីមួយនៅក្នុងគ្រួសារ គឺតួនាទីជាអ្នកអប់រំ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ទៅកាន់គ្រីស្តបរិស័ទ នៅពេលចូលរួម ក្នុងពិធីអប់រំជំនឿដល់គ្រីស្តបរិស័ទថា នេះគឺជាពេលវេលាដែលឪពុកនិងម្តាយត្រូវតែវិលត្រឡប់ទៅរកកូន ។

តាមវិទ្យុវ៉ាទីកង់ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានដាស់តឿនគ្រីស្តបរិស័ទថា ជាអាណាព្យាបាលគ្រីស្តបរិស័ទ គឺមិនត្រូវ និរទេសខ្លួនឯងពីគ្រួសារជាពិសេស គឺពីកូនរបស់ខ្លួនឡើយ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ អាណាព្យាបាល មានតួនាទីសំខាន់ណាស់ នៅក្នុងការអប់រំ ដូច្នេះសូមយកចិត្តទុកដាក់ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ថា កុមារដែលអាចរីកចំរើនបានប្រកបដោយគន្លងធម៌នោះ គឺដាច់ខាតគឺមិនអាចអត់មានគ្រួសារជាពិសេស គឺអាណាព្យាបាល ដែលអប់រំប្រៀនប្រដៅបានឡើយ ។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ទំនាក់ទំនងរវាងអាណាព្យាបាល និងកុមារ គឺជាគំនិត ប្រកបដោយភាពវិជ្ជមាននៃវឌ្ឍនភាព សង្គមប្រកបដោយគុណធម៌ ៕

# ស្ថាប័នហិរញ្ញវត្ថុធំៗអះអាងអំពីកំណើនសេដ្ឋកិច្ចដ៏វិជ្ជមាន ប៉ុន្តែ ពលរដ្ឋសាមញ្ញមិនយល់




*អគារខ្ពស់ៗដែលទើបនឹងសាងសង់និងសាងសង់រួចនៅទីក្រុងភ្នំពេញបច្ចុប្បន្ន ។ រូបថត:លីហៀង*

ស្ថាប័នសេដ្ឋកិច្ចពិភពលោក និង តំបន់ធំៗ ដែលបានតាមដាន និង អង្កេត អំពីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា គឺសុទ្ធតែអះអាងអំពីកំណើនសេដ្ឋកិច្ច ប្រកបដោយភាពវិជ្ជមាន របស់ប្រទេសកម្ពុជា ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋសាមញ្ញមិនយល់ ហើយថែមទាំងពោលថា កំណើននេះដូចជាមិនពាក់ព័ន្ធជាមួយពួកគេ ។

របាយការណ៍ថ្មីមួយ ដែលចេញផ្សាយដោយស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ និង ធនាគារពិភពលោក ដែលមានមូលដ្ឋាន នៅវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ក៏ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានទីស្នាក់ការធំនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន គឺបានអះអាងព្រមគ្នាថា កំណើនសេដ្ឋកិច្ចរបស់កម្ពុជា គឺនៅក្នុងកំរិតមួយដ៏វិជ្ជមាន ។

មូលនិធិរូបិយវត្ថុអន្តរជាតិបានអះអាងថា នៅក្នុងឆ្នាំ ២០១៥ នេះ កម្ពុជារំពឹងថា នឹងទទួលបានកំណើនសេដ្ឋកិច្ចប្រមាណជា ៧,២ភាគរយ។ ប្រភពដដែលបានឲ្យដឹងថា សម្រាប់ឆ្នាំ២០១៦ស្ថាប័ននេះរំពឹងដដែលថា កម្ពុជា នឹងទទួលកំណើនសេដ្ឋកិច្ចនៅក្នុងរង្វង់ប្រមាណ ជា៧,២ ភាគរយផងដែរ ។

ប្រភពដដែលបានឲ្យដឹងថា សម្រាប់ឆ្នាំ ២០១៥នេះ ការព្យាករណ៍នៃកំណើនសេដ្ឋកិច្ចកម្ពុជា គឺ នៅទទួលបានលំដាប់ទីបី បន្ទាប់ពីឡាវ ដែលគេទស្សន៍ទាយថា នឹងទទួលបាន ៧,៣ ភាគរយហើយភូមា គឺ៨,៣ភាគរយ។

ការព្យាករណ៍កំណើន សេដ្ឋកិច្ចកម្ពុជា ក្នុងឆ្នាំ២០១៥និងឆ្នាំ២០១៦ របស់ មូលនិធិរូបិយវត្ថុអន្តរជាតិ គឺនៅកណ្តាល រវាងធនាគារ អភិវឌ្ឍន៍អាស៊ី និង ធនាគារពិភពលោក។

បើតាមការព្យាករណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីបានអះអាងថា កម្ពុជានៅក្នុងឆ្នាំ ២០១៥នេះរំពឹងថា នឹងទទួលបានកំណើនប្រមាណជា ៧,៣ ភាគរយ និងនៅក្នុងឆ្នាំ ២០១៦ គឺ ៧,៥ភាគរយ ដោយឡែកធនាគារពិភពលោក គឺទាំងឆ្នាំ ២០១៥ និង ២០១៦ គឺកម្ពុជាអាចទទួលកំណើនសេដ្ឋកិច្ចប្រមាណជា6,៩ភាគរយ ។

នេះគឺជាស្ថានភាព នៃការព្យាករណ៍កំណើន នៃសេដ្ឋកិច្ចកម្ពុជាដ៏វិជ្ជមាន របស់បណ្តាអ្នកសេដ្ឋកិច្ចវិទូ របស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ប៉ុន្តែសម្រាប់ពលរដ្ឋសាមញ្ញវិញ គឺហាក់ដូចជា នៅតែមិនយល់អំពីកំណើននេះ ហើយបានអះអាងថា ប្រហែលជាគ្មានទំនាក់ទំនងអ្វីជាមួយពួកគេទេ ដោយសារពេលនេះ អ្វីៗដែលគេទស្សទាយថា ល្អជាប់គ្នាប៉ុន្មានឆ្នាំហើយ ប៉ុន្តែស្ថានភាពពួកគេ គឺនៅដែដែល ។

អង្គុយនៅលើម៉ូតូ ក្រោមម្លប់ នៃអាគារខ្ពស់មួយនៅម្តុំប្លុកបឹងកេងកង កំពុងរង់ចាំម៉ូយ លោក ខេង ចំរើន អ្នករត់ម៉ូតូមួយរូប បានអះអាងលោកបានឮអ្នកនយោបាយមន្ត្រីរដ្ឋាភិបាលធំៗ វិទ្យុ ទូរទស្សន៍ និយាយអំពីកំណើនសេដ្ឋកិច្ចនេះជាប្រចាំ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ មកដល់ពេលនេះគឺ ជីវភាពរបស់គាត់ និង គ្រួសារ នៅតែមានស្ថានភាពដដែល ដោយគ្មានអ្វីកែប្រែឡើយ។

លោកបាននិយាយថា សម្រាប់គ្រួសារគេ ក្រែងលោគេមានការប្រែប្រួលតែគ្រួសាររបស់លោក គឺនៅតែដដែល។ ស្ថានភាពពីមុនយ៉ាងម៉េច គឺនៅតែដដែល ប្លែកតែមួយទេ គឺកូនវាធំៗ ហើយកំពុងតែពេញរៀន ពេញហូបតែប៉ុណ្ណោះ ។

លោកបានបញ្ជាក់ថា "អត់យល់គេថា រីកចំរើនៗ ប៉ុន្តែសម្រាប់ខ្ញុំ តាំងពី ១០ឆ្នាំមុនមករត់ម៉ូតូនៅទីក្រុង មកដល់ពេលនេះនៅតែរត់ម៉ូតូហើយកូនខ្ញុំកម្មការនីរោងចក្រកាត់ដេរ នៅតែជាកម្មកកាត់ដេរ ពួកយើងនៅផ្ទះជួល គឺនៅតែផ្ទះជួល"។

ប្រជាពលរដ្ឋមួយរូបទៀត ដែលមានមុខរបរលក់ការ៉េម តាមម៉ូតូកែច្នៃឈ្មោះ នីត សំរេច ឲ្យដឹងថានារយៈពេលប៉ុន្មានឆ្នាំនេះ វាប្រែប្រួល គឺប្រែប្រួលហើយ គឺផ្លូវមានឡានច្រើន ស្ទះចរាចរណ៍ក៏ច្រើន មនុស្សក៏ច្រើនទេសចរណ៍ក៏ច្រើនដែរ ប៉ុន្តែសម្រាប់លោក គឺដូចជាមិនមានអ្វីដែលគួរឲ្យប្រែប្រួលជាដុំកំភួនឡើយ ។

លោកបានបញ្ជាក់ថា "ការប្រែប្រួលរបស់ខ្ញុំ គឺមានតែពីមុនលក់ការ៉េម ជាក់ស៊ីក្លូកែច្នៃ តែពេលនេះ មកបើកម៉ូតូ ប៉ុន្តែរឿងរស់នៅ ហូបចុក កន្លែងស្នាក់នៅគឺដដែលទាំងអស់"។

លោកបានឲ្យដឹងទៀតថា "យើងនៅតែស៊ីផ្អក ប្រហុកដដែលៗ អត់ដែលស្គាល់ភីហ្សាអីនឹងគេទេ ឃើញតែរូប និងអក្សរ"។

កញ្ញា ចាន់ កេសរ ជាអ្នករត់តុហាងបាយមួយរូប បានអះអាងថា សម្រាប់កញ្ញាផ្ទាល់និងគ្រួសារក៏គ្មានអ្វីដែលប្រែប្រួលគួរឲ្យកត់សំគាល់ដែរ ទាំងប្រាក់ខែ ទាំងការងារ ទាំងជីវភាព ដោយសារតែស្ថានភាពនេះ គឺហាក់ដូចជាដដែលៗសម្រាប់នាង ។

កញ្ញាបានបញ្ជាក់ថា "ខ្ញុំដូចជាអត់មានអ្វីប្លែកទេ ខ្ញុំនៅតែជាអ្នករត់តុ ម៉ែនិងឪនៅតែស្រែ តែឆ្នាំនេះខ្ញុំមានប្អូនប្រុសមួយរូបនៅក្នុងបន្ទុក ដោយគេមករៀននៅភ្នំពេញ និងស្នាក់នៅជាមួយតែប៉ុណ្ណោះ ក្រៅពីនេះគឺដដែល ផ្ទះជួលក៏មិនដូរ របស់របរ ឆ្នាំងចានក៏មិនដូរដែរ"។

ជុំវិញបញ្ហាទាំងនេះ មន្ត្រីនៅក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុមួយរូប ដែលសុំមិនបញ្ចេញអត្តសញ្ញាណបាន មានប្រសាសន៍ថា កំណើនសេដ្ឋកិច្ចនេះ គឺជាកំណើនអរូបិយ ហើយអ្នកសេដ្ឋកិច្ច គឺរាប់ទាំងអស់ តាំងពីការចំណាយ តាំងពីចំណូលរបស់ប្រជាពលរដ្ឋ រដ្ឋ ក្រុមហ៊ុនឯកជន ប៉ុន្តែគេធ្វើជារួម ។

លោកបានអះអាងថា ការគណនាអំពីកំណើនសេដ្ឋកិច្ចនេះ គេអត់គិតអំពីថា អ្នកនោះជាមហាសេដ្ឋី ជាអ្នកក្រីក្រ ដើរសុំទាន ឬយ៉ាងណាទេ គឺគេប្រមូលចំណូល និងចំណាយទាំងអស់បូកបញ្ចូលគ្នា ហើយចែកជាមធ្យមភាគតែម្តង។

លោកបានឲ្យដឹងថា យើងទាំងអស់គ្នា អាចមើលឃើញកំណើននេះតាមតែវត្ថុតាងទេ គឺដូចជា សម្ភារប្រើប្រាស់ កំណើនយានយន្ត កំណើននៃការអភិវឌ្ឍន៍ ហើយឧទាហរណ៍ជាក់ស្តែង រឿងតម្លើងប្រាក់ខែកម្មករ និង កម្មការនី មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធនេះជាដើម។

លោកបានបញ្ជាក់ថា "ឃើញអត់ឡានបើកពេញទីក្រុង អាគារខ្ពស់ៗជាច្រើន ការឡើងប្រាក់ខែ នេះហើយជារូបភាពនៃកំណើនសេដ្ឋកិច្ច"៕

**ដោយអរិយបុត្រ**

# ២០ឧសភា យុវជនខ្លះដឹងខ្លះមិនដឹងខណៈប្រទេសរៀបចំទិវានេះពេញប្រទេស



*ព្រះសហគមន៍ធ្វើពិធីរំឭកខួបទី៤០ឆ្នាំនៃទិវាចងកំហឹងក្នុងរបបប៉ុល ពត ដែលបានកាប់សម្លាប់ប្រជាជនខ្មែរអស់ ជាង៣លាននាក់ ។រូបថត: Bunroeun*

យុវជនកម្ពុជា ទំនងជាមិនសូវចាប់អារម្មណ៍នឹងទិវាចងកំហឹង នឹងរបប ប៉ុល ពត ខ្មែរក្រហម ដែលត្រូវបាន គេរៀបចំឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី២០ ខែឧសភា ដោយសារតែខ្លះដឹង ហើយខ្លះទៀតមិនដឹងដោយឡែក អ្នកដែលដឹងក៏ទំនងជាដឹងដោយប្រយោលឬដោយចៃដន្យ ។

ទិវាចងកំហឹងនឹងរបប ប៉ុល ពត មិនស្ថិតនៅក្នុងពិធីបុណ្យជាតិ ដែលតម្រូវឲ្យមន្ត្រីរាជការ កម្មករ និយោជិត និស្សិត និងសិស្សសាលាឈប់សម្រាកឡើយ ប៉ុន្តែពិធីនេះ ជាពិធីដែលពលរដ្ឋកម្ពុជា បានរៀបចំ សឹងតែគ្រប់ខេត្ត ដើម្បីបង្ហាញអារម្មណ៍ចងចាំជានិច្ចនូវភាពឈឺចាប់ ខ្លោចផ្សាសាហាវយង់ឃ្នង និងការកាប់សម្លាប់របស់ពួក ប៉ុល ពត ដែលបានធ្វើមកលើប្រជាជនខ្លួនឯងហើយបានប្ដេជ្ញារួមគ្នាទប់ស្កាត់មិនឲ្យរបបដ៏ឃោរឃៅនេះវិលត្រលប់ ឬកើតមកសាជាថ្មីវិញឡើយ។

នៅក្នុងថ្ងៃទី២០ ខែឧសភា ឆ្នាំនេះគឺជាថ្ងៃគម្រប់ខួបទី ៤០ឆ្នាំ ថ្ងៃ ២០ ឧសភា ១៩៧៥- ២០ ឧសភា ២០១៥ នៃការប្រកាសដាក់ឲ្យអនុវត្តនូវគោលនយោបាយ របស់របបប្រល័យពូជសាសន៍ ប៉ុល ពតដើម្បីអនុវត្តមាគ៌ាបដិវត្តន៍សមូហភាព ។ ថ្ងៃ ២០ ឧសភា ឆ្នាំ១៩៧៥ ក៏ជាថ្ងៃចាប់ផ្តើម នៃការប្រល័យជីវិតប្រជាជនខ្មែរយ៉ាងវង្គាលផងដែរ។

ដើម្បីរម្លឹកដល់ថ្ងៃដ៏សែនខ្លោចផ្សាក្រោម ការដឹកនាំរបស់ខ្មែរក្រហមនៅថ្ងៃ២០ ឧសភានេះ ប្រជាពលរដ្ឋកម្ពុជាមួយចំនួន គឺនៅតែចង់ចាំព្រឹត្តិការណ៍នោះ ហើយនាំគ្នារៀបចំពិធីនេះជាបន្តបន្ទាប់ ប៉ុន្តែយុវជនភាគច្រើន ហាក់មិនសូវចាប់អារម្មណ៍នឹងពិធីជាប្រវត្តិសាស្ត្រនេះបានឡើយ ។

កំពុងតែទិញសៀវភៅ នៅក្នុងបណ្ណាគារមួយកន្លែង នៅមុំសាលាបឋមសិក្សាបាក់ទូក យុវជន សាញ់ សាវ៉ាន់ ដែលអះអាងថា មានអាយុ ២៤ ឆ្នាំ ជានិស្សិតភាសាអង់គ្លេសបានឲ្យដឹងថា អត់បានដឹងថា នៅថ្ងៃទី២០ ខែឧសភានេះជាថ្ងៃអីផង។

សាវ៉ាន់ បានបញ្ជាក់ថា "អត់ដឹង ខ្ញុំទៅរៀនធម្មតា អត់មាននរណាឈប់អីផង"។

យុវនារីជ័យ សុភា ជាមន្ត្រីរដ្ឋបាលនៅក្រុមហ៊ុនមួយ បាននិយាយថា តាមកញ្ញាបានដឹងថ្ងៃនេះ គឺជាថ្ងៃទិវាចងកំហឹងនឹងរបប ប៉ុលពត ដែលគេដឹងថា បានសម្លាប់ប្រជាពលរដ្ឋប្រមាណជា៣ លាននាក់ ហើយគេប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ។

កញ្ញា សុភា បានបញ្ជាក់ថា "ខ្ញុំដឹង ពីព្រោះកាលនោះ មេខ្ញុំ គឺគាត់តេ (ទូរស័ព្ទ)មកខ្ញុំថា អត់បានមកក្រុមហ៊ុនទេនៅពេលព្រឹក ដោយសារទៅចូលរួមទិវានេះ កាលពី ថ្ងៃទី២០ ខែឧសភា"។

លោក ទេព សុខវឌ្ឍនា ជាយុវនិស្សិតមួយរូបបានអះអាងថា លោកមិនបានដឹងតែម្តងថា មានអ្វីនៅក្នុងថ្ងៃទី ២០ ខែឧសភានេះ នៅពេលដែលសួរថា "តើប្អូនដឹងថា នៅថ្ងៃទី ២០ ខែមិថុនា នេះមានព្រឹត្តិការណ៍អ្វី? ចម្លើយដែលបានគឺ "ខ្ញុំអត់ដឹងផង ហើយថ្ងៃ២០ ខែឧសភា ដូចជាអត់មានអីពិសេសនោះទេ"។

វឌ្ឍនា បានបង្ហាញអារម្មណ៍ជ្រួតជ្រាបបន្តិចឡើងវិញ នៅពេលដែលមានការបង្ហើបប្រាប់ អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយនេះ ។

វឌ្ឍនា បានបញ្ជាក់ថា "អូហ៍! មែនថ្ងៃនេះជាថ្ងៃចងកំហឹង ខ្ញុំក៏ធ្លាប់ចូលរួមម្តង ពីរដងដែរ កាលនៅក្នុងក្រុមកាយឫទ្ធិកាលនៅវិទ្យាល័យ"។

ពិធីនេះមិនមែនជាពិធីបុណ្យជាតិ ប៉ុន្តែត្រូវបានរៀបចំឡើង នៅគ្រប់ខេត្តគ្រាន់តែពេល និង កាលបរិច្ឆេទ គឺខុសៗគ្នា ហើយទីកន្លែងក៏ខុសគ្នាផងដែរ ប៉ុន្តែសម្រាប់នៅរាជធានីភ្នំពេញគេតែងប្រារព្ធរៀបចំ ពិធីរំឭកខួបនិងគោរពវិញ្ញាណក្ខន្ធជនរងគ្រោះដ៏ធំមួយ នៅវាលពិឃាតបឹងជើងឯកដែលជាកន្លែងសម្លាប់មនុស្ស ក្នុងរបបខ្មែរក្រហមបន្ទាប់ពីអ្នកទាំងនោះត្រូវបានបញ្ជូន ចេញពីគុកទួលស្លែងនិងកន្លែងផ្សេង។

លោក សុខ រចនា ជាមន្ត្រីចូលនិវត្តន៍មួយរូបបានអះអាងថា យុវជននិងយុវនារីសម័យនេះ គឺអាចភ្លេចបានដោយសារតែវា មិនមែនជារឿងដែលពួកគេបានឆ្លងកាត់ ប៉ុន្តែបើសិនជាសម្រាប់អ្នកដែលបានឆ្លងកាត់ គឺមិនអាចបំភ្លេចបានទេ នៅការឈឺចាប់និងទុក្ខវេទនាសម័យនោះ។

លោក រចនា បានបញ្ជាក់ថា "ក្មេងៗប្រហែលជាមិនចាំទេ ព្រោះគេមិនដែលបានហែលឆ្លង។ ការមើលឯកសារ ស្តាប់ចាស់ៗនិយាយម្តង ពីរដង គឺគេភ្លេចហើយ តែដូចជាខ្ញុំអីប្រហែលជាចាំម៉ាជីវិតនោះ"។

លោកបានបន្តទៀតថា មិនធម្មតាទេ មនុស្សសម័យនោះ (សម័យខ្មែរក្រហម)មហាវេទនាម្នាក់ៗរស់ដោយការឈឺចាប់ សេចក្តីតក់ស្លុត និងភាពភ័យខ្លាចនៅតែដក់ជាប់ក្នុងអារម្មណ៍គិតមើលទៅ សូម្បីតែកូនខ្លួនឯងទើបនឹងកើត ក៏មិនឲ្យនៅជាមួយនឹងម៉ែឪដែរ។

លោកបានបញ្ជាក់ថា "ខ្ញុំព្រាត់កូនមួយទល់ឥឡូវ មិនដឹងថា រស់ឬស្លាប់ ដោយសារសម័យនោះ អង្គការគេប្រមូលយកទៅ ដល់ពេលវៀតណាមចូលមក ខ្ញុំរត់ទៅរកកូនមិនដឹងជារត់ទៅណា ពីព្រោះគេនៅតូចណាស់ កាលនោះអាយុ ៣ ឆ្នាំ អត់ស្គាល់មុខម៉ែឪផង"។

ទាក់ទងនឹងការឈឺចាប់ ទុក្ខវេទនាការបាត់បង់សាច់ញាតិ នៅក្នុងសម័យនេះ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែសហការគ្នា ជាមួយនឹងដំណើរការកាត់ទោស បណ្តាមេដឹកនាំខ្មែរក្រហមដែលរួមមានលោក ខៀវ សំផន អតីតប្រមុខរដ្ឋ របស់របស់ខ្មែរក្រហម លោក អៀង សារី អតីតរដ្ឋមន្ត្រីការបរទេស និង លោក នួន ជា អតីតប្រធានរដ្ឋសភានៃរបបនេះ។

មកដល់ពេលនេះ សាលាក្តីនេះកំពុងតែបន្តដំណើរការ ស្វែងរកយុត្តធម៌ជូនប្រជាពលរដ្ឋកម្ពុជា នៅឡើយទេទោះបីជាសាលាក្តីនេះកំពុងតែប្រឈមមុខ នឹងបញ្ហាវិបត្តិថវិកាខ្លះៗក៏ដោយ។

គម្រោងថវិកាកែសម្រួលថ្មី សម្រាប់ឆ្នាំ ២០១៤-២០១៥ របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានអនុម័តដោយក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗ

គម្រោងថវិកាកែសម្រួល សម្រាប់ឆ្នាំ ២០១៥ នេះ សរុបមានចំនួន ៣៣,៨ លានដុល្លារ ក្នុងនោះ ២៧,១ លានដុល្លារ សម្រាប់ភាគីអន្តរជាតិ និង ៦,៧ លានដុល្លារ សម្រាប់ភាគីជាតិ៕

**ដោយអរិយបុត្រ**

# ការត្រាស់ហៅក្នុងការត្រាស់



សមាជិកក្រុមបេណេឌីកតូ (លោកដាមីញ៉ាំង លោកវិន័យ និងលោកប៊្រុយណូ)

*ក្រុមគ្រួសារបេណេឌីកតូ នឹងចាប់ផ្តើមរូបរាងជាថ្មីលើទឹកដីកម្ពុជា ក្នុងពេលខាងមុខនេះ បន្ទាប់ពីក្រុមបព្វជិតនេះបានអវត្តមានក្នុងសម័យ ប្រល័យពូជសាសន៍ប៉ុលពត ក្នុងឆ្នាំ ១៩៧៥ មកដល់ពេលនេះ។ បច្ចុប្បន្នលោកបូជាចារ្យកូសម៍ ប៊្រុយណូ រួមនឹងលោកបូជាចារ្យ ចំនួន២នាក់ទៀត បានកំពុងរិះគិតនិងប្រជុំគ្នា ដើម្បីបង្កើតក្រុមបព្វជិតនេះឡើងវិញ ។ សំណួរនិងចម្លើយខាងក្រោមនេះ នឹងជួយអ្នកអាន បានជ្រាបអំពីរបៀបរស់នៅ កិច្ចការ និងសកម្មភាពរបស់ក្រុមនេះ។*

**អ្នកនាំសារ ៖** តើក្រុមបព្វជិត បេណេឌីកតូ មានរបៀបរស់នៅយ៉ាងដូចម្តេច?

**លោកកូសម៍ ប៊្រុយណូ ៖** តាំងពី ១៥០០ឆ្នាំមុន មានក្រុមនេះក្នុងព្រះសហគមន៍។ ក្រុមនេះសម្រាប់បុរស គឺដើម្បីបម្រើព្រះសហគមន៍ ដើម្បីអធិដ្ឋាន ដើម្បីផ្តល់សក្ខីភាពអំពីព្រះសហគមន៍ ដែលជាសញ្ញានៃព្រះរាជរបស់ព្រះជាម្ចាស់ ក្នុងលោកនេះ។ក្រុមនេះគឺគ្មានសកម្មភាពតាមព្រះសហគមន៍ ដូចយើងធ្លាប់ស្គាល់ទេ។ ភាគច្រើនគឺរស់នៅជាមួយគ្នាដោយអធិដ្ឋាននៅកន្លែងស្ងាត់ៗ មិនមែននៅក្នុងកណ្តាលទីក្រុងឡើយ ។ ការរស់នៅរបស់ក្រុមនេះ គឺមិនតឹងរឹងដូចក្រុមបងស្រីកាមែល (បងស្រីសម្ងាត់) ដោយសារយើងដឹងថា បងស្រីនៅក្នុងអារាមរហូត (តែ)សម្រាប់លោកផ្សេង (លោក)អាចចេញបានពេលណាក៏បាន ប្រហែលអាចទៅតាមព្រះសហគមន៍ ធ្វើកម្មវិធីអ្វីមួយបាន។ ប៉ុន្តែគឺភាគច្រើននៅក្នុងអារាមអធិដ្ឋាន និងរស់នៅជាមួយគ្នា។ គោលបំណងនៃអារាមនេះ គឺទទួលភ្ញៀវដែលចង់អធិដ្ឋាន ដែលចង់សំណាក់ធម៌ ដែលចង់រិះគិតអំពីជំនឿរបស់គេ។ ហើយគ្រីស្តបរិស័ទអាចទៅអារាមសួរសុខទុក្ខ សំណាក់ធម៌ ថ្វាយអភិបូជា អធិដ្ឋាន (នៅក្នុងអារាម)។ នេះជាតួនាទីនិងជាបេសកកម្មក្រុមបព្វជិតបេណេឌីកតូ។

**អ្នកនាំសារ ៖** ហេតុអ្វីបានជាលោកផ្លាស់ប្តូរជីវិតជាសាសនទូត ទៅជាបព្វជិតវិញ?

**លោកកូសម៍ ប៊្រុយណូ ៖** ម៉្យាងខ្ញុំផ្លាស់ប្តូរមែន តែម៉្យាងខ្ញុំមិនផ្លាស់ប្តូរទេ! ខ្ញុំជាសាសនទូតដូចគ្នា។ ឧទាហរណ៍ ខ្ញុំដូចលោក ដាមី ញ៉ាំង ដូចលោកវិន័យ យើងជាបូជាចារ្យភូមិភាគ។ ពីរនាក់មកពីខាងក្រៅនិងម្នាក់នៅស្រុកខ្មែរ។ ហើយយើងបីនាក់ យើងចង់បម្រើព្រះសហគមន៍ យើងចង់ប្រកាសដំណឹងល្អ យើងចង់ធ្វើជាសាក្សីរបស់ព្រះយេស៊ូគ្រីស្តក្នុងកន្លែងរស់នៅរបស់យើង។ របៀបរស់នៅរបស់យើងផ្លាស់ប្តូរ ដោយសារយើងរស់នៅក្នុងអារាមមួយ យើងធ្វើការជាមួយគ្នា ប៉ុន្តែគោលបំណងតែមួយគឺបន្តប្រកាសដំណឹងល្អ បន្តធ្វើជាសាក្សីរបស់ព្រះជាម្ចាស់ ឲ្យអ្នកដទៃបានស្គាល់។ ខ្ញុំសង្ឃឹមច្រើន បើយើងរស់នៅតាមរបៀបនេះ អត់ដឹងនៅកន្លែងណា យើងនៅតែបន្តនាំឲ្យបងប្អូនឯទៀតៗប្រហែលអ្នកនៅក្នុងភូមិជាមួយយើង បងប្អូនពុទ្ធបរិស័ទបានស្គាល់ព្រះសហគមន៍ បានស្គាល់ព្រះយេស៊ូគ្រីស្ត។ ដូច្នេះអត់មានអីខុសគ្នា(ពីបូជាចារ្យភូមិភាគ)។ របៀបរស់នៅខុសគ្នាខ្ញុំទទួលស្គាល់ ក៏ប៉ុន្តែយើងមិនរស់នៅដូចតាបស់ឥសី ។ យើងមិននៅលើភ្នំ មិនម្នាក់ឯង។ យើងចង់បន្ត ទាក់ទងជាមួយសង្គមរបស់យើង បងប្អូនរបស់យើងជាពុទ្ធបរិស័ទផង ជាកាតូលិកផង ក៏ប៉ុន្តែ (តាម)របៀបថ្មី។

**អ្នកនាំសារ ៖** តើលោកទំនាក់ទំនងជាមួយមនុស្ស នៅក្នុងសង្គមតាមរបៀបណាខ្លះ?

**លោកកូសម៍ ប៊្រុយណូ ៖** យើងអាចទទួលមនុស្សច្រើន ដែលចង់ជួបយើង អ្នកចង់ទៅថ្វាយអភិបូជា ចង់ជួបលោកចង់ឲ្យមានសំណាក់ធម៌ អត់មានបញ្ហាយើងទទួល។ នេះជាតួនាទីរបស់ក្រុមសន្តបេណេឌីកតូ។ ដូចកាលពីមុននៅកែប ក្រុមសន្តបេណេឌីកតូរស់នៅក្នុងអារាមរបស់គេ ប៉ុន្តែអ្នកនៅក្នុងភូមិ គេស្គាល់លោកទាំងអស់ដោយសារលោកចេញ ប្រហែលទៅផ្សារមានន័យថាមានទំនាក់ទំនង។ មិនមែនមានន័យថា យើងចូល និងបិទទ្វារ។ ក៏ប៉ុន្តែត្រូវទទួលស្គាល់យើងចង់ចាប់អារម្មណ៍ច្រើនជាង ពីរបៀបអធិដ្ឋាននិងរបៀបធ្វើការដើម្បីចិញ្ចឹមជីវិត។ នេះជាចំណុចដ៏សំខាន់។

**អ្នកនាំសារ ៖** តើក្រុមបព្វជិតបេណេឌីកតូអាចប្រើប្រាស់ទូរស័ព្ទ ឬអ៊ីនធឺណេត ដើម្បីទំនាក់ទំនងទៅខាងក្រៅបានទេ?

**លោកកូសម៍ ប៊្រុយណូ ៖** ជីវិតរស់នៅរបស់យើង យើងត្រូវបង្ហាញរបៀបសាមញ្ញដែរ ។អនាគត(ក្រុមបព្វជិត) ត្រូវការបន្តប្រើទូរស័ព្ទ និងអ៊ីនធឺណេត ដោយសារ ជារបៀបនៃការទាក់ទងជាមួយគ្នា ប៉ុន្តែសាមញ្ញជាង ។ ក្នុងអារាម យើងលែងគិត អំពីប្រយោជន៍ផ្ទាល់ខ្លួន តែយើងចាប់ផ្តើមគិតពីប្រយោជន៍យើងទាំងអស់គ្នា ។ប្រហែលនៅពេលអនាគតទូរស័ព្ទអាចមានតែមួយ និងមានកុំព្យូទ័រមួយខ្ញុំអត់ដឹង ប៉ុន្តែខ្ញុំគិតថាវាល្មមហើយ។

**អ្នកនាំសារ ៖** តើក្រុមបព្វជិតនេះនឹងបង្កើតជារូបរាង នៅពេលណា ?

**លោកកូសម៍ ប៊្រុយណូ ៖** ឥឡូវនេះ យើង (ត្រូវបាន) ទទួលស្គាល់ជាផ្លូវការហើយពីលោកអភិបាល (ព្រះសហគមន៍កាតូលិក)ទាំងបី។ យើងកំពុងរិះគិតជាមួយគ្នាថាយើងនឹងទៅកន្លែងណាដើម្បីទទួលបទពិសោធន៍ពីក្រុមនេះ។ ប្រហែលនៅបារាំង ដោយសារយើងបីនាក់ និយាយភាសាបារាំង និងយើងកំពុងរកកន្លែងមួយ របស់ក្រុមបព្វជិតបេណេឌីកតូ ដែលអាចទទួលយើង ដើម្បីទទួលការអប់រំ។ ក្រោយមកយើងនឹងត្រឡប់មកស្រុកខ្មែរវិញ ដើម្បីចាប់ផ្តើមរស់នៅលើទឹកដីខ្មែរប៉ុន្តែអត់ទាន់ដឹងនៅកន្លែងណា។

**អ្នកនាំសារ ៖** តើក្រុមលោកនឹងចេញទៅបារាំងក្នុងពេលណាដែរ?

**លោកកូសម៍ ប៊្រុយណូ ៖** យើងកំពុងរស់ចាំដំណឹងពីលោក (ក្រុមបេណេឌីកតូនៅបារាំង) ដែលនឹងទទួលយើង។ ប្រហែលយើងអាចទៅក្នុងខែ ១០ ឬ១១ (តុលាឬវិច្ឆិកា) ខាងមុខនេះ។

**អ្នកនាំសារ ៖** តើលោកយល់ថា ការផ្លាស់ប្តូរពីបូជាចារ្យភូមិភាគនេះ អាចធ្វើឲ្យព្រះសហគមន៍ខ្វះខាតធនធានមនុស្ស ដើម្បីបម្រើសង្គមដែរទេ?

**លោកកូសម៍ ប៊្រុយណូ ៖** ខ្ញុំលោកដាមីញ៉ាំង លោកវិន័យ មិនចង់ចេញពីព្រះសហគមន៍ទេ។ ប្រហែលយើងចេញពីកន្លែងរស់នៅរបស់យើង ។ ប៉ុន្តែគោលបំណងមានតែមួយ (គឺ) បន្តបម្រើព្រះសហគមន៍ បន្តជួយព្រះសហគមន៍ អធិដ្ឋានសម្រាប់ព្រះសហគមន៍ ជួយយុវជន រិះគិតអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ ជួយអ្នកដទៃឲ្យគេយល់អំពីដំណឹងល្អ ដែលយើងទទួលពីព្រះជាម្ចាស់។ ពិតមែនបើយើងគិតភ្លាមៗថា គួរឲ្យស្តាយដោយសារខ្វះលោក អ្នកណាជួយតាមព្រះសហគមន៍ឥចឹងទៅ។ ប៉ុន្តែយើងមិនចង់គិតតែអំពីសកម្មភាពការងារផ្សេងៗច្រើន យើងចង់គិតអំពីជីវិតខាងវិញ្ញាណរបស់យើង និងជីវិតជាមួយព្រះយេស៊ូគ្រីស្តដែរ។

**អ្នកនាំសារ ៖** តើលោកគិតថា ពេលអនាគត នឹងមានយុវជនចង់បម្រើព្រះសហគមន៍តាមការរស់នៅ របស់ក្រុមបព្វជិត បេណេឌិកតូនេះដែរទេ ដោយសារបច្ចុប្បន្ន ព្រះសហគមន៍កំពុងមានតម្រូវការបូជាចារ្យ ដើម្បីចាត់ចែងនិងដឹកនាំ?

**លោកកូសម៍ ប៊្រុយណូ ៖** បាទ ខ្ញុំសង្ឃឹម ប៉ុន្តែច្បាស់ហើយ ខ្ញុំមិនដឹងប៉ុន្មាន។ ប៉ុន្តែខ្ញុំជឿថាត្រូវតែមាន។ ព្រះជាម្ចាស់ មានគម្រោងការផ្សេងដែលនាំឲ្យយើងជាលោក ដាមីញ៉ាំង លោកវិន័យ និងខ្ញុំបានសម្រេចចិត្តរបៀបនេះ៕

**ដោយ កល្បព្រឹក្ស**

# កម្មករនិងអ្នកជួលផ្ទះរអ៊ូរឿងកុងទ័រភ្លើងដើរលឿន



ការតភ្ជាប់បណ្តាញអគ្គិសនីនៅក្នុងទីក្រុងភ្នំពេញ ។រូបភាព(ឯកសារ)

បណ្តាកម្មករ និងកម្មការនី និងអ្នកដែលរស់នៅផ្ទះជួល ដែលបានមានឱកាសតបណ្តាញភ្លើង ពីរដ្ឋបានធ្វើការកត់សម្គាល់ថា កុងទ័រភ្លើងដែលរដ្ឋបានប្រើប្រាស់ នឹងភ្ជាប់ជំនួយឲ្យកុងទ័រភ្លើងចាស់ ដែលពួកគាត់ធ្លាប់ប្រើ គឺហាក់ដូចជាលឿនជាងកុងភ្លើងដែលពួកគាត់ធ្លាប់បានប្រើប្រាស់របស់ផ្ទះជួលពីមុនមក។

ការប្រៀបធៀបគ្នា រវាងបរិមាណគីឡូវ៉ាត់ម៉ោង ដែលបណ្តាអ្នកស្នាក់នៅផ្ទះជួល ធ្លាប់ប្រើប្រាស់ភ្លើងកុងទ័រម្ចាស់ផ្ទះជួល និងចំនួនគីឡូវ៉ាត់ម៉ោងនៃកុងទ័រភ្លើង ដែលបានភ្ជាប់ដោយអគ្គិសនីកម្ពុជា គឺធ្វើឡើងក្រោយពេលដែលពួកគេ បានតភ្លើងពីបណ្តាញអគ្គិសនីរបស់អគ្គិសនីកម្ពុជា បានមួយខែរួចមក។

លោកស្រី ញៀន បញ្ញាព័ណ អ្នករស់នៅផ្ទះជួល ម្តុំសាលាបឋមសិក្សាពញាក្រែក ទល់មុខនឹងអគ្គិសនីចាស់ បានអះអាងទាំងញ័រមាត់ថា "អូយកុងទ័រភ្លើងដើរលឿនណាស់ ។

លោកស្រីបានបញ្ជាក់ថា "តម្លៃថោកមែន ប៉ុន្តែកុងទ័រភ្លើងដើរញាប់លើសពីការគិត របស់ខ្ញុំតាំងពីដំបូងមកឆ្ងាយណាស់"។

លោកស្រីបានអះអាងថា "កាលពីមុន ខ្ញុំប្រើមួយខែអស់ត្រឹមតែប្រមាណជា២០០គីឡូ (គីឡូវ៉ាត់ម៉ោង) អីទេ ប៉ុន្តែក្រោយតភ្លើងរដ្ឋហើយ ដល់ខែក្រដាសវិក័យប័ត្រភ្លើងចេញមក គឺអស់រហូតដល់ទៅ ៣០០ គីឡូ"។

លោកស្រីបានអះអាងថា ចាំមើលប្រើខែនេះទៀត បើសិនជាវានៅតែអស់ច្រើនដូច្នេះ លោកស្រីនឹងទៅសួរនាំនៅអគ្គិសនីកម្ពុជាខ្លះៗហើយ ដើម្បីចង់ដឹងអំពីមូលហេតុ ។

លោកស្រី បានបញ្ជាក់ថា " ខ្ញុំប្រើរបស់ដដែលទាំងអស់ ហើយម៉ោងពេលប្រើប្រាស់ក៏ដដែលដែរ ប៉ុន្តែហេតុអ្វី បានជាវាអស់ច្រើនជាងបែបនេះ ឥចឹងហើយបានជាឆ្ងល់"។

សព្វថ្ងៃនេះ សម្ភារដែលអ្នកស្រីបានប្រើប្រាស់ជាមួយនឹងអគ្គិសនី គឺរួមមានម៉ាស៊ីនត្រជាក់កំរិតមួយសេសមួយ ទូរទស្សន៍តូចមួយគ្រឿង កង្ហារ និង អំពូល ព្រមទាំងឆ្នាំងអ៊ុត ឆ្នាំងដាំបាយប៉ុណ្ណោះ អត់មានបានបន្ថែមអ្វីនោះទេ ប៉ុន្តែបរិមាណគឺច្រើនប្លែកដល់ទៅជាង១០០ គីឡូវ៉ាត់ម៉ោង។

លោកស្រី បានបញ្ជាក់ទៀតថា លោក ស្រី ខំតែអរនៅពេលដែលបានតបណ្តាញភ្លើងរដ្ឋ ដោយសារតែតម្លៃវាខុសគ្នាដល់ទៅពាក់កណ្តាល គឺ ៦១០ រៀលទល់នឹង ១.២០០ រៀល ប៉ុន្តែអរអី វិក័យប័ត្រចេញមក គឺស្រងាកចិត្តហើយលោកស្រីបានចំណាយបង់ភ្លើងលើសមុនថែមទៀត ។

លោកស្រីបានបញ្ជាក់ថា "ខំតែសង្ឃឹមសល់លុយ ២០.០០០ ទៅ ៣០.០០០ រៀល គ្រាន់ឲ្យកូនទិញនំ ប៉ុន្តែនេះ គឺអស់លើសមុនទទៀត"។

លោកស្រីបានបញ្ជាក់ថា "បើខ្ញុំប្រើច្រើននោះមិនថាទេ ប៉ុន្តែអ្វីៗគឺតាមធម្មតាទាំងអស់ ហេតុអីបានជាវាច្រើនបែបនេះ"។

កញ្ញា រុន ភត្រា អ្នករស់នៅផ្ទះជួលនៅម្តុំផ្សារទទូលសង្កែ ក៏បានកត់សំគាល់អំពីកំណើន នៃបរិមាណគីឡូវ៉ាត់ម៉ោងដែលកញ្ញា និងមិត្តភ័ក្របានប្រើប្រាស់ដូចគ្នា ។

កញ្ញាបានអះអាងថា "កាលពីមុនជាមួយនឹងកូនកង្ហារ៣ អំពូល៣ ឆ្នាំងដាំបាយអគ្គិសនី ១ ខ្ញុំប្រើអស់ភ្លើងតែ ៣០ទៅ៤០គីឡូទេ ប៉ុន្តែខែនេះចេញវិក័យប័ត្រភ្លើងមក គឺជិត៧០គីឡូ"។

កញ្ញបានបញ្ជាក់ទៀតថា "ថ្លៃវាថោកមែន ប៉ុន្តែគីឡូវាដើរលឿនដូច្នេះ ខែនេះ និងខែមុន គឺកញ្ញាបង់លុយដូចតែដូចហ្នឹង គឺអស់ ៦០.០០០ ទៅ ៧០.០០០ រៀលដដែលៗ"។

កញ្ញា ចេត ស៊ុរ៉ាវី ជាកម្មការនីរោងចក្រម្តុំចាក់អង្រែក្រោម បានអះអាងថា កញ្ញាមិនទាន់បានដឹងអំពីបញ្ហានេះទេ ប៉ុន្តែចេះតែឮគេល្បីតៗគ្នាអំពីបញ្ហានេះ។

កញ្ញាបានបញ្ជាក់ថា "ចាំមើលគេចេញវិក័យប័ត្រសិន ពីព្រោះទើបតែបានប្រើមិនទាន់បានឃើញ "។

កញ្ញា បានបន្តទៀតថា នៅមុនពេលតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋ គឺកញ្ញា និងមិត្តភក្តិដែលរស់នៅជុំគ្នាប្រើប្រាស់អគ្គិសនីអស់ត្រឹមតែ ២០ ទៅ ៣០គីឡូវ៉ាត់ម៉ោងតែប៉ុណ្ណោះ។

ជុំវិញបញ្ហាកុងទ័រភ្លើងនេះ បុគ្គលិកផ្នែកតបណ្តាញ អគ្គិសនីកម្ពុជាមួយរូប ដែលសុំមិនបញ្ចេញឈ្មោះ បានឲ្យដឹងថា បញ្ហានេះវាអាចមកពីអ្នកដែលប្រើប្រាស់ ឬមកពីកុងទ័រ ហើយបើមិនអស់ចិត្ត គឺអាចឡើងទៅជួបជាមួយនឹង មន្ត្រីនៅការិយាល័យនោះគេនឹងបញ្ជូនភ្នាក់ងារ ចុះមកពិនិត្យដល់កន្លែងផ្ទាល់ ។

លោកបានបន្តទៀតថា មូលហេតុដែលចំនួនគីឡូវាដើរលឿន គឺវាអាចដោយសារបញ្ហាមនុស្ស ពីព្រោះកាលនៅតម្លៃ១.២០០ រៀលនៅក្នុងមួយគីឡូវ៉ាត់ម៉ោង គឺសន្សំសំចៃ តែដល់បានភ្ជាប់អា៦១០រៀល គឺគិតតែពួយដោយសារតែវាថោក ដូច្នេះក៏លើសបែបនេះ។ ម្យ៉ាងវិញទៀត គឺអាចមានករណីកត់កុងទ័រខុស ។

រហូតមកដល់ពេលនេះ អគ្គិសនីកម្ពុជាបានអះអាងថា យុទ្ធនាការចុះភ្ជាប់ចរន្តតម្លៃ ៦១០រៀល ជូនដល់អ្នកជួលផ្ទះ/ជួលបន្ទប់ នៅក្រោមការចែកចាយផ្ទាល់ របស់អគ្គិសនីកម្ពុជានៅរាជធានីភ្នំពេញ គឺបានចាប់ផ្តើមតាំងពីថ្ងៃទី២៩ ខែមករាមកដល់យប់ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ គឺបានតភ្ជាប់បណ្តាញ ដែលមានថ្លៃអនុគ្រោះជូនដល់អ្នកក្រីក្រប្រើប្រាស់ក្រោម ៥០ គីឡូវ៉ាត់ម៉ោង ក្នុងមួយខែបាន ៦៥.៨០៦ បន្ទប់រួចហើយ ។ រហូតមកដល់ពេលនេះ នៅក្នុងចំណោមអ្នកដែលស្នាក់នៅផ្ទះជួល ឬបន្ទប់ជួល ភាគច្រើនគឺជាកម្មករ និងកម្មការនីរោងចក្រកាត់ដេរ ដែលមានចំនួនប្រមាណជា ៧០០.០០០នាក់ ដែលកំពុងតែបំរើការ លើផលិតកម្មឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌនៅកម្ពុជា ខណៈដែលវិស័យនេះ គឺជាផលិតផលនាំចេញ មានបរិមាណសរុបប្រមាណជា ៨០ ភាគរយនៃផលិតផលនាំចេញសរុបរបស់កម្ពុជា ។

ក្រៅពីកម្មករ និងកម្មការនីរោងចក្រកាត់ដេរចេញ អ្នកដែលរស់នៅផ្ទះជួល ក៏មានយុវជន និងយុវនារី ដែលជានិស្សិតដែលបានកំពុងតែស្វែងរកចំណេះវិជ្ជានៅតាមទីក្រុង ព្រមទាំងក្រុមបុគ្គល ដែលកំពុងតែបំរើការនៅក្នុងផ្នែកសេវាកម្មនានា នៅក្នុងប្រទេស រាប់ទាំងសេវាកម្មកំសាន្ត បុគ្គលិកអង្គការសង្គមស៊ីវិលហើយក៏មានមន្ត្រីរាជការ ដែលមានទីលំនៅ នៅតាមខេត្តនានា ឆ្ងាយពីកន្លែងធ្វើការជាច្រើនផងដែរ៕

**ដោយអរិយបុត្រ**



# ២០១៥! ពលរដ្ឋមើលឃើញ

បញ្ហាបរិស្ថាន អនាម័យ ការស់នៅស្អាតរបស់ប្រជាពលរដ្ឋ នៅរាជធានីភ្នំពេញ នៅតែប្រឈមនឹងបញ្ហាសំរាម ទោះឆ្នាំនេះឆ្នាំ២០១៥សល់តែប៉ុន្មានខែទៀត ដល់ពេលត្រូវធ្វើសមាហរណកម្មអាស៊ានក៏ដោយចុះ។

លោក ហេង ចំណូល អ្នកប្រកបរបររត់ម៉ូតូឌុបពេលរាត្រីមួយរូប បានឲ្យដឹងថា សំរាមត្រូវបានចាក់គរសឹងតែគ្រប់ផ្លូវនៅរាជធានីភ្នំពេញ ជាពិសេស គឺនៅតាមតំបន់ជុំវិញផ្សារនានានៅក្នុងរាជធានី ។

លោកបាននិយាយ របៀបលេងសើចផងបានឲ្យដឹងថា ជាអ្នកក្រីក្រមានមុខរបររត់ម៉ូតូឌុបពេលរាត្រី ក្រៅពីបារម្ភរឿងសុវត្ថិភាពផ្ទាល់ខ្លួន ជាពិសេស គឺរឿងចោរប្លន់ និងរឿងគ្រោះថ្នាក់ចរាចរណ៍ គឺគាត់នៅបារម្ភមួយទៀត គឺជិះបុកភ្នំសំរាម ដែលគេយកមកចោលនៅតាមដងផ្លូវ។

លោកបានបញ្ជាក់ថា "ជិះម៉ូតូពេលរាត្រី បើសិនជាមិនស្គាល់ភូមិសាស្ត្រទេ ភ្លើងមិនសូវភ្លឺ គឺច្បាស់ជាបុកភ្នំសំរាមដួលងាប់មិនខាន។ តាមផ្សារតាមអី គឺភាគច្រើនតែម៉ោង ៧ ទៅម៉ោង៩យប់អី គឺសំរាមចាក់គរ



*សំរាមដែលពលរដ្ឋយកមកគរចោលនៅតាមថ្នល់មុខដីឡូ៍ដែលគ្មានម្ចាស់នៅថៃរក្សា ។*

នៅកណ្ដាលផ្លូវតែម្ដង"។

តាមការអះអាង របស់លោកចំណូលមកដល់ពេលនេះ កន្លែងដែលលោកធ្លាប់ឃើញគំនរភ្នំសំរាម នៅពេលរាត្រី គឺមានដូចជាច្រើនជាងគេនៅម្ដុំជុំវិញផ្សារអូឫស្សី ផ្សារដើមគរ ផ្សារកណ្ដាល ពោលគឺនៅតាមផ្សារ និង តាមកន្លែងដែលមានសំណង់ផ្ទះល្វែងច្រើនលើក្រោម។

លោកបានអះអាងថា ក្រៅពីម៉ូតូឌុប អ្នកជិះម៉ូតូឯទៀត នៅចន្លោះម៉ោង៧ ទៅ១០យប់អី ពេលជិះម៉ូតូ ឬឡានពេលនោះ សូមប្រយ័ត្នភ្នំសំរាម ពីព្រោះលោកធ្លាប់ឃើញអ្នកបើកបរម៉ូតូបុកគំនរសំរាមដួល ក្រឡិតដៃ ក្រឡិតជើង អស់មុខអស់មាត់តែញឹកញាប់ហ្នឹង។ ពេលខ្លះអ្នកបើកបរឡាន ភ្ញាក់នឹងគំនរសំរាម គេចទៅបុកអ្នកដំណើរផ្សេងទៀត ក៏ធ្លាប់ឃើញដែរ ដូច្នេះសូមប្រយ័ត្ន ។ ជុំវិញបញ្ហាយកសំរាមទៅចោលតាមទ្រូងផ្លូវនេះ អ្នកចោលសំរាមមួយរូបដែលអះអាងថាឈ្មោះ ជា ឡាយ ជាប្រជាពលរដ្ឋម្នាក់ នៅម្ដុំផ្សារអូឫស្សីជាន់ទីបី បានឲ្យដឹងថា នេះជាទម្លាប់មករាប់សិបឆ្នាំហើយ ទោះបីជាលោកស្រី និងប្រជាពលរដ្ឋឯទៀតមិនចង់ក៏ដោយ ។

លោកស្រីបានឲ្យដឹងថា គ្មាននរណាចង់ យកសំរាមនេះទៅចោលនៅកណ្ដាលវាលផ្លូវបែបនេះនោះទេ ប៉ុន្តែវាគ្មានកន្លែងដាក់ ទើបនាំគ្នាចាក់គរនៅលើផ្លូវបែបនេះ។ លោកស្រីបានបន្តទៀតថា ដំបូងឡើយ លោកស្រី និងអ្នកឯងទៀត គឺយកសំរាមដាក់តែលើចិញ្ចើមផ្លូវទេ ប៉ុន្តែក្រោយមក សំរាមវាច្រើនពេក ជួលកាលស៊ីនទ្រីប្រមូលមិនទាន់ ទុកគរនៅមុខផ្ទះគេ ម្ចាស់ផ្ទះនៅខាងក្រោមគេក៏លែងឲ្យដាក់មុខផ្ទះគេ ដូច្នេះមិនដឹងជាដាក់នៅទីណា ក៏ចោលកណ្ដាលផ្លូវទៅ រង់ចាំឡានសំរាមមកដល់។

លោកស្រីបានបញ្ជាក់ថា "នរណាក៏ចង់ស្អាត ចង់ល្អដែរ ប៉ុន្តែរឿងសំរាមនេះ វាទាល់ទីតែម្ដង មិនដឹងទៅចោលឯណា ឥឡូវនេះអត់មានកន្លែងចាក់សំរាមទេ ធុងធំៗក៏គ្មានដែរ"។

ក្រៅពីទីប្រជុំជនធំៗ ដែលមានសំរាមច្រើន រហូតដល់មានការចាក់គរនៅតាមទ្រូងផ្លូវចេញ បណ្ដាប្រជាពលរដ្ឋ ដែលរស់នៅតាមផ្ទះល្វែង

## ក្រសួងបរិស្ថានកំពុងរៀបចំដាក់ចេញគម្រោងបច្ចេកវិទ្យាគ្រប់គ្រងសំរាម

លោក សៅ សុភាព អ្នកនាំពាក្យក្រសួងបរិស្ថានបានមានប្រសាសន៍ថា បញ្ហាសំរាមគឺជាបញ្ហាកង្វល់មួយដ៏ចំបងរបស់ក្រសួង ហើយនៅពេលនេះ ក្រសួងកំពុងតែគិតគូរបញ្ហានេះជាមួយនឹងសាលារាជធានីភ្នំពេញ។

លោកបានមានប្រសាសន៍បញ្ជាក់ កាលពីថ្ងៃទី១៨ ខែឧសភាថា ក្រសួងបរិស្ថាន និងសាលារាជធានីភ្នំពេញ គឺកំពុងតែប្ដេជ្ញារួមគ្នា ថានឹងអនុវត្តគម្រោងបច្ចេកវិទ្យាដ៏ប្រសើរមួយ ដើម្បីគ្រប់គ្រងសំណល់រឹងឲ្យបាននៅក្នុងរយៈពេល៥ឆ្នាំ ។

ជុំវិញបញ្ហាសំរាម ឬកាកសំណល់នេះ លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងនៅក្នុងកិច្ចប្រជុំថ្នាក់តំបន់មួយ នៅថ្ងៃដដែលនោះថា កំណើនប្រជាពលរដ្ឋការរីកចម្រើនផ្នែកសេដ្ឋកិច្ច និងភាពលូតលាស់យ៉ាងឆាប់រហ័ស ផ្នែកនគរូបនីយកម្ម បានបង្កើនបរិមាណសំណល់រឹង-រាវនៅកម្ពុជាយ៉ាងឆាប់រហ័ស ជាពិសេសនៅតាមទីប្រជុំជន។

លោកបន្តថា ដើម្បីដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់ជាកញ្ចប់ថវិកាអនាម័យបរិស្ថាន ចំនួន៥លានដុល្លារអាមេរិក ដើម្បីពង្រឹងការគ្រប់គ្រងសំណល់រឹង-រាវ។ កញ្ចប់ថវិកានេះត្រូវបានប្រើប្រាស់សម្រាប់គ្រប់គ្រងសំណល់រឹង-រាវក្នុងបណ្ដាខេត្តក្រុងចំនួន ២៦ លើកលែងរាជធានីភ្នំពេញ។

លោកបានថ្លែងបន្តទៀតថាសំរាមនេះ គឺជាប្រភពនៃសារជាតុគីមពុល បញ្ហាអនាម័យ និងជាប្រភពនៃបញ្ហាច្រើន ដែលអាចបង្កជាផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពមនុស្ស និងសុវត្ថិភាពបរិស្ថានពិភពលោក។

លោកបានបន្តទៀតថា ប្រសិនបើមិនបានគ្រប់គ្រងត្រឹមត្រូវទេនោះ សំរាមអាចផ្លាស់ប្ដូរគុណភាពខ្យល់ ទឹក និងអាចប៉ះពាល់ដល់សុខភាព។

លោករដ្ឋមន្ត្រី បានថ្លែងពីបច្ចុប្បន្នភាពនៃការកែទម្រង់វិស័យបរិស្ថាននៅកម្ពុជា តាមរយៈការធ្វើទំនើបកម្មក្រសួងបរិស្ថាន ដើម្បីឈានទៅសម្រេចគោលបំណងជាយុទ្ធសាស្ត្រទាំងបី គឺកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវចម្រុះ និងការរស់នៅដោយចីរភាព។ លោកបានគូសបញ្ជាក់ថា គម្រោងសកម្មភាពអនុវត្តន៍បច្ចេកវិទ្យាដ៏ប្រសើរដែលអាចរកបាននិងការប្រត្តិបត្តិបរិស្ថានដ៏ប្រសើរ នៅទីលានចាក់សំណល់ ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា ដើម្បីឆ្លើយតបទៅនឹងអនុសញ្ញាស្តុកខូម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុនេះ និងរួមចំណែកដល់គោលបំណងជាយុទ្ធសាស្ត្រទាំងបីនេះ៕

# បញ្ហាសំរាមនៅតែមិនរៀបរយ



រូបថត: ឡុង សម្ផស្ស

និងនៅតាមបុរីនានា ក៏បានលើកឡើងអំពីការកកស្ទះសំរាមនេះផងដែរ ។

លោក លី ឡាយ ប្រជាពលរដ្ឋមួយរូប នៅព្រែកប្រា ខណ្ឌច្បារអំពៅ បានឲ្យដឹងថា ពេលខ្លះមួយសប្តាហ៍ អត់មាននរណា មកប្រមូលសំរាមក៏មាន។

លោកបានបញ្ជាក់ថា "ខ្ញុំពេលខ្លះ អាណាវាធាប់ស្អុយរលួយ គឺត្រូវបង្ខំចិត្ត ដឹកម៉ូតូយកទៅបោះចោលតាមផ្សារ"។

កំពុងតែប្រមូលសំរាម កើបដាក់ឡាន កម្មករប្រមូលសំរាមមួយរូប បានអះអាងថា សំរាមឥឡូវនេះច្រើនណាស់។ "ម៉ាថ្ងៃៗ កើបមិនចង់ទាន់វាច្រើនពេក" នេះគឺជាសំដីរបស់កម្មករប្រមូលសំរាមរូបនេះ ។

លោក គឺជាកម្មករប្រមូលសំរាមវេនយប់ ពីម៉ោង ៥ ទៅដល់ ម៉ោង ៩ យប់ ប៉ុន្តែដោយសារតែសំរាមវាច្រើន ពេលគឺពេលខ្លះ ត្រូវធ្វើការដល់ម៉ោង ១០យប់ក៏មានដែរ។

លោកបានបន្តទៀតថា នៅក្នុងមួយឡាន គឺមានគ្នាតែ ៤នាក់ទេ តែសំរាមវិញ គឺមានច្រើន ទាំងខ្លះគេចងដាក់តាមមុខផ្ទះ រហូតដល់សំរាមតាមផ្លូវដែលមានជាច្រើនគំនរ។ សំរាមដែលគេចងត្រឹមត្រូវ គឺមិនសូវជាពិបាកទេ គ្រាន់តែលើកដាក់ចូលឡានប៉ុណ្ណោះ ប៉ុន្តែរឿងដែលពិបាកនោះ គឺថាខ្លះ គឺចាក់គរអត់មានថង់ អត់មានអី ដែលបង្ខំចិត្តត្រូវឈប់ឡានរួចនាំគ្នាកើប។ លោកបានបន្តថា សំរាមតាមផ្ទះ គឺភាគច្រើនមានការវេចខ្ចប់ដាក់ថង់ស្រួលប្រមូល ប៉ុន្តែនៅតាមទីផ្សារភាគច្រើន គឺគរជាគំនរ អត់មានថង់ អត់មានអីនោះទេ។

នេះគឺជាបញ្ហាដដែលៗ អំពីសំរាមដែលកើតមាន នៅក្នុងតំបន់តាមទីប្រជុំជន កណ្តាលរាជធានីភ្នំពេញ ដែលជាបេះដូងរបស់ប្រទេស ជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច រដ្ឋបាល និងប្រវត្តិសាស្ត្ររបស់កម្ពុជា ប៉ុន្តែ នៅតាមតំបន់ជាយរាជធានីវិញ ក្រៅពីប្រឈមមុខ នឹងបញ្ហាកកស្ទះសំរាម ក៏ដូចជាប្រជាពលរដ្ឋនៅកណ្តាលរាជធានី ហើយនោះក៏នៅប្រឈមមុខនឹងបញ្ហាមួយទៀត រឿងសំរាមនេះដែរ ។

លោក សៅ រង្សី ជាប្រជាពលរដ្ឋមួយរូបនៅសង្កាត់សែនសុខ បានឲ្យដឹងថា បញ្ហាសំរាមនេះ គឺនៅក្នុងសហគមន៍រស់នៅរបស់លោក ក៏កំពុងតែមានបញ្ហាផងដែរ ដោយសារតែ សំរាមប្រមូលមិនទាន់ជារឿយៗ គឺមានលេចចេញនូវបាតុភាពផ្សេងៗ គឺដូចជាប្រជាពលរដ្ឋនាំគ្នាយកសំរាមទៅចោលនៅកន្លែងសាធារណៈ ឬកន្លែងណាមួយ ដែលពួកគេអាចចោលបាន ហើយអ្នកខ្លះ គឺសុខចិត្តគរសំរាមនោះឲ្យស្ងួតហើយដុតកំទិចខ្លួនឯង ហើយអ្នកខ្លះទៀត គឺជីកដីជាគ្រលុក ដាក់សំរាមផ្ទាល់នៅក្នុងគ្រួសារ។ លោកបានអះអាង ថា "ករណីដូចជាគ្រួសាររបស់ខ្ញុំ គឺសំរាមជាថង់ផ្លាស់ស្ទិកអី គឺខ្ញុំទុកម្តុំសម្រាប់ដុតចោល សំបកកំប៉ុង ដបអីទុកលក់អេតចាយ ហើយរបស់ដែលរលួយ គឺដាក់នៅក្នុងរណ្តៅសំរាម ដែលជីកទុកធ្វើជីដាំដើមឈើ"។

លោកបានអះអាងថា នេះគឺជាវិធីងាយៗ ដែលលោកកំពុងតែអនុវត្ត ដោយសារតែសំរាមជួនកាល មួយអាទិត្យ ជួនកាលកន្លះខែ ទើបបានមានគេមកប្រមូលម្តង។

លោកបានបន្តទៀតថា ការកកស្ទះសំរាមនេះគឺជាបញ្ហា ដូច្នេះហើយបានជាអ្នកខ្លះ ដែលរស់នៅផ្ទះល្វែង គ្មានកន្លែងចោល គ្មានកន្លែងដុត គឺត្រូវបង្ខំចិត្ត ប្រមូលសំរាមទៅបោះចោលនៅកន្លែងណា ដែលពួកគេអាចបោះបាន ទើបបង្ករឲ្យមានការប៉ះពាល់ដល់សោភ័ណភាព អនាម័យនៅតាមភូមិ ។

លោកបានបញ្ជាក់ថា "កន្លែងខ្លះឲ្យតែជាដីទំនេរ ម្ចាស់អត់នៅអត់មានអ្នកចាំ ម្នាក់ពីនាក់បោះសំរាមនៅទីនោះ យូរៗទៅគឺមនុស្សមួយភូមិយកសំរាមទៅចោលនៅទីនោះ" ។

រហូតមកដល់ពេលនេះ នៅក្នុងទូទាំងរាជធានីភ្នំពេញ ដែលមានប្រជាពលរដ្ឋអចិន្ត្រៃយ៍រស់នៅប្រមាណជា ១,៥ លាននាក់ គឺបានបន្សល់ទុក្ខ ឬធ្វើឲ្យមានសំណល់ សរុបប្រមាណជា១.៥០០តោន ទៅ ១.៧០០តោន នៅក្នុងមួយថ្ងៃ ហើយអាជ្ញាធររាជធានីភ្នំពេញ បានប៉ាន់ប្រមាណថានឹងអាចកើនឡើងរហូតដល់ទៅ២០០០តោន នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំខាងមុខ។ សំរាមទាំងនោះ គឺសម្រាប់តែជាសំរាមសំណល់ផ្ទះបាយ និងការប្រើប្រាស់ទូទៅ សម្រាប់ជីវភាពប្រជាពលរដ្ឋប៉ុណ្ណោះ ក្រៅពីនោះ នៅមានសំណល់ពីមន្ទីរពេទ្យ និងសំណល់ពីរោងចក្រឧស្សាហកម្ម ថែមមួយចំនួនទៀត៕

**ដោយអរិយបុត្រ**

## ប្រភេទនៃសំរាមឬកាកសំណល់នៅកម្ពុជា

ក្រសួងបរិស្ថានបានពិពណ៌នាថា សំរាមគឺជារបស់របរដែលអស់តម្លៃ គ្មានប្រយោជន៍ ឬវត្ថុដែលគេលែងត្រូវការប្រើប្រាស់ ឬអស់តម្រូវការហើយមានបំណងបោះបង់ចោល ឬតម្រូវឱ្យបោះបង់ចោល។

ផ្អែកទៅតាមការសិក្សា និងឆ្លងកាត់នូវការធ្វើវិភាគទៅលើសំរាម និងកាកសំណល់ គេអាចធ្វើការបែងចែកសំរាមជាបីប្រភេទផ្សេងៗពីគ្នា ដែលមានដូចជាសំណល់រឹង ដែលជាផលិតផល ឬជាកម្ទេចកម្ទីដែលត្រូវបានគេបោះបង់ចោលដូចជា សម្បកដប កែវ លោហៈធាតុ កំប៉ុងជាដើម និងប្រភេទសំណល់ពីផ្ទះបាយ។ សំណល់ទីពីរ គឺប្រភេទសំណល់រាវ ដែលជាកាកសំណល់ ដែលគេបញ្ចេញតាមបណ្តាញប្រព័ន្ធលូទឹកស្អុយផ្សេងៗ ហើយប្រភេទទីបី គឺជាប្រភេទសំរាមដែលគ្រោះថ្នាក់ដែលទាមទារការប្រុងប្រយ័ត្នខ្ពស់។

ក្រសួងបរិស្ថានបានឲ្យដឹងថា សំរាមប្រភេទនេះ គឺភាគច្រើនមានប្រភពចេញពីរោងចក្រឧស្សាហកម្ម និងសហគ្រាសដែលប្រើប្រាស់សារធាតុគីមីច្រើន សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និងសេវាកម្មអាជីវកម្មរ៉ែ មន្ទីរពេទ្យ ដែលកំពុងតែទាមទារឲ្យមានការយកចិត្តទុកដាក់ដែរ។

ក្រសួងបរិស្ថានបានអះអាងថា ថ្វីត្បិតតែប្រជាពលរដ្ឋភាគច្រើនគិតថាសំរាមទាំងនេះ វាមានតម្លៃសម្រាប់ពួកគេ ប៉ុន្តែប្រភេទភាគច្រើននៅសេសសល់តម្លៃខ្លះសម្រាប់ការយកមកកែច្នៃឡើងវិញ ដូចជាគេអាចទាញយកថាមពលអគ្គិសនី ជីវធម្មជាតិ ។ល។

# ព្រះសហគមន៍តាខ្មៅទទួលសមាជិកជាគ្រីស្តបរិស័ទដំបូង



*យុវជនលំ សេរីវឌ្ឍន៍ ទើបទទួលអគ្គសញ្ញាជ្រមុជទឹក។*

ព្រះសហគមន៍កាតូលិក ក្រុងតាខ្មៅ បានទទួលយុវជនដំបូងម្នាក់ ឲ្យធ្វើអគ្គសញ្ញាជ្រមុជទឹក ក្លាយជាគ្រីស្តបរិស័ទកាលពីថ្ងៃទី១០ ឧសភា ក្រោមអធិបតីភាពរបស់ លោកបូជាចារ្យ ម៉ារីយ៉ូហ្គេស្ស៊ី ទទួកបន្ទុកមណ្ឌលសកម្មភាពតាខ្មៅ រួមនិងគ្រីស្តបរិស័ទ និង ពុទ្ធបរិស័ទជាង ២០០នាក់។

យុវជនលំ សេរីវឌ្ឍន៍ បានឲ្យដឹងថា "ខ្ញុំចូលព្រះសហគមន៍ព្រោះខ្ញុំជឿលើព្រះជាម្ចាស់ មិនមែនដើម្បីផលប្រយោជន៍ទ"។ សេរីវឌ្ឍន៍ជាសិស្សដែលបានរៀនសូត្រនៅសាលាអង្គការរបស់ព្រះសហគមន៍កាតូលិក ដែលគ្រប់គ្រងដោយក្រុមបងប្រុសម៉ារីស្ត។ តាមរយៈ ការសិក្សានៅក្នុងសាលា គាត់បានចូលស្វែងយល់ អំពីគ្រីស្តសាសនា។ សេរីវឌ្ឍន៍ បានរំឭកថា ក្រោយពេលស្គាល់ ព្រះសហគមន៍ គាត់យល់ឃើញថា មានភាពខុសគ្នាស្រឡះនូវអ្វីដែលគាត់បានឮអំពីភាពអវិជ្ជមានរបស់គ្រីស្តសាសនា ដែលពលរដ្ឋទូទៅនិយាយ។

ព្រះសហគមន៍តាខ្មៅ ស្ថិតនៅខេត្តកណ្តាល ជាមណ្ឌលសកម្មភាពថ្មីមួយបង្កើតឡើងក្នុងឆ្នាំ ២០១៤។ បច្ចុប្បន្នមានគ្រីស្តបរិស័ទ ចំនួន៧នាក់រួមទាំងយុវជនលំ សេរីវឌ្ឍន៍៕

**ដោយអ៊ុក សំនៀង**

# សិក្ខាសាលាស្វែងយល់អំពីរបៀបកសាងសង្គមសុខដុមរមនា

វិទ្យាស្ថានសន្តប៉ូល បានរៀបចំសិក្ខាសាលាមួយស្តីអំពី "គុណតម្លៃដើម្បីកសាងសង្គមកម្ពុជា នៅសតវត្សទី២១" រួមសហការជាមួយអង្គការយូនីស្កូផ្នែកសិទ្ធិមនុស្ស និងសាកលវិទ្យាល័យប៊ឺហ្គាម៉ូ នៃប្រទេសអ៊ីតាលី ពីថ្ងៃទី១៨ ដល់២០ ឧសភា ដែលមានសិក្ខាកាមចូលរួមចំនួន ១៦៥នាក់ ដែលជានិស្សិត បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថានសន្តប៉ូល នាយកវិទ្យាល័យទាំង១២ នៃវិទ្យាល័យក្នុងខេត្តតាកែវ តំណាងអង្គការសង្គមស៊ីវិល តំណាងការិយាល័យ ព្រះសហគមន៍កាតូលិក សាស្ត្រាចារ្យតំណាងសាកលវិទ្យាល័យប៊ឺហ្គាម៉ូ រួមជាមួយវត្តមានដ៏ខ្ពង់ខ្ពស់របស់លោកអភិបាលអូលីវីយេ ឆ្មឹតអ៊ីស្លែរ អភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ និងជានាយកវិទ្យាស្ថានសន្តប៉ូល ។

សិក្ខាសាលា បានរិះគិតអំពីគុណតម្លៃ និងប្រយោជន៍រួម ដែលបង្ហាញដោយវាគ្មិន មកពីសាកលវិទ្យាល័យប៊ឺហ្គាម៉ូនៃប្រទេសអ៊ីតាលី។ ការរិះគិតអំពីបញ្ហាប្រឈមនានា នៅក្នុងប្រទេសកម្ពុជា ដែលបានបង្ហាញដោយលោកសាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានសន្តប៉ូល។ គុណតម្លៃដើម្បីកសាងសង្គម ប្រកបដោយសុខដុមរមនា តាមទស្សនៈនៃសាសនាធំៗទាំងបីនៅកម្ពុជា និងទស្សនៈពីសង្គមស៊ីវិល រិះគិតពីតួនាទីរបស់ពលរដ្ឋ ក្នុងការកសាងសង្គមបច្ចុប្បន្ន។

លោកអូលីវីយេ ឆ្មឹតអ៊ីស្លែរ បានមានប្រសាសន៍ថា ពេលខាងមុខនេះកម្ពុជា និងចូលសមាហរណកម្មអាស៊ានជាផ្លូវការ។ ហើយក៏ជាឱកាសមួយដើម្បីនិស្សិត និងសាស្ត្រាចារ្យរិះគិតពីគុណតម្លៃដើម្បីកសាងសតវត្សទី២១ ទោះបីជាយើងដឹងថា រដ្ឋាភិបាល បានរៀបចំគោលការណ៍នយោបាយ និងសេដ្ឋកិច្ចយ៉ាងច្បាស់លាស់ក៏ដោយ ក៏វិទ្យាស្ថានយល់ថា គួរតែមានវិធីមួយដែលជួយដល់សង្គមក្នុងការកសាងចិត្តគំនិតដែរ។

លោកបន្តថា៖ សិក្ខាកាមចាប់ផ្តើមយល់ និងភ្ញាក់ស្មារតីអំពីរបៀបដែលត្រូវបង្កើតភាតរភាព រវាងអ្នកជុំវិញខ្លួន និងរវាងប្រទេសទាំងអស់ក្នុងអាស៊ាន ទាំង១០ប្រទេស ជាពិសេសបានឃើញពីសារៈសំខាន់នៃការសន្ទនា និងការអប់រំមនុស្សតាំងពីកំរិតមត្តេយ្យ រហូតដល់សាកលវិទ្យាល័យ ដើម្បីកសាងចិត្តគំនិត។ លោកអូលីវីយេ បានបន្ថែមទៀតថា៖ រយៈពេល ៣ថ្ងៃកន្លងមកនេះ គឺជាឱកាសមួយក្នុងបើកចិត្តគំនិត ដើម្បីទទួលការអប់រំអំពីជីវិត និង ជាពិសេសដើម្បីទទួលកម្លាំង ដោយយល់ថាយើងជាពលរដ្ឋ បានចូលរួមយ៉ាងសកម្មក្នុងសង្គមដែរ ហើយសូមកុំគិតថារឿងអភិវឌ្ឍប្រទេស គឺជារឿងរបស់អ្នក ដឹកនាំប្រទេសតែប៉ុណ្ណោះ តែគឺជាតួនាទីរបស់យើងម្នាក់ៗ ផងដែរ។

យុវនារី កែវផន អង្គារស្មី ជានិស្សិតវិទ្យាស្ថានសន្តប៉ូល បានឲ្យដឹងថា៖ ប៉ុន្មានថ្ងៃកន្លងមកនេះសិក្ខាសាលាបានជួយ ឲ្យនាងទទួលបានទាំងព័ត៌មាន និងចំណេះដឹងថ្មីៗអំពីរបៀបកសាងសង្គមក្នុង សតវត្សទី២១ ដោយស្វែងយល់ពីចំនុចល្អ នៃសាសនានីមួយៗនិងចេះចងមិត្តភាពជាមួយសាសនាដទៃ។ កញ្ញាបានឲ្យដឹងទៀតថា៖ ប្រសិនបើយើងយល់ដឹងពីអត្ថប្រយោជន៍ នៃសាសនាទាំងនោះ នាំឲ្យយើងចូលក្នុងទីផ្សារអាស៊ាននាពេលខាងមុខដោយសន្តិភាពគ្មានជំលោះសាសនា។



*សិក្ខាកាមនិងវាគ្មិនកិត្តិយសថតរូបអនុស្សាវរីយ៍នៅមុខបណ្ណាល័យវិទ្យាស្ថានសន្តប៉ូល។ ដោយសម្ផស្ស*

លោកស្រី សាស្ត្រាចារ្យ ស្ទេផានៀ ហ្គានដូលហ្វូ (Stephania Gandolfo) មកពីសកលវិទ្យាល័យ ប៊ឺហ្គាមូ ប្រទេស អ៊ីតាលី បានមានប្រសាសន៍ថា៖ នេះពិតជាជោគជ័យមួយដ៏ប្រសើរ នៃអង្គសិក្ខាសាលានេះ ព្រោះគ្រប់គ្នាចូលរួមយ៉ាងសកម្ម ជាពិសេសគឺយុវជនបានបញ្ចេញគំនិត និងការយល់ដឹងរបស់ខ្លួនពិតៗ។

ពេលបញ្ចប់ អង្គសិក្ខាសាលា សិក្ខាកាមទាំងអស់ ក៏បានចេញនូវសេចក្តីប្រកាសរួមទុកជាអនុសាសន៍ដើម្បីអភិវឌ្ឍសង្គមកម្មកម្ពុជា ក៏ដូចជាសហគមន៍អាស៊ាន ពេលធ្វើសមាហរណកម្មសេដ្ឋកិច្ច និង វប្បធម៌រួមគ្នានាពេលអនាគត ដោយសង្កត់ធ្ងន់ថា៖ "មនុស្សមានតម្លៃ និងសេចក្តីថ្លៃថ្នូរស្មើៗគ្នា ដែលមិនអាចកាត់ថ្លៃបាន ហើយមនុស្សជាស្នូលនៃគុណតម្លៃ ក្នុងគ្រប់ការសម្រេចចិត្តទាំងអស់ ដែលនាំឲ្យរកឃើញនូវផលប្រយោជន៍រួម តាមរយៈការគោរពសិទ្ធិតម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ប្រកបដោយការទទួលខុសត្រូវ និងការចូលរួមជួយគ្នាទៅវិញទៅមកយ៉ាង សកម្មក្នុងសាមគ្គីភាព និងភាតរភាព.....!" ៕

**ដោយដាលីស**

# ព័ត៌មានទូទៅ

## សាលារាជធានីសំរេចបង្កើតភ្នាក់ងារអនាម័យតាមសង្កាត់

សាលារាជធានីភ្នំពេញ នៅព្រឹកថ្ងៃទី២៥ ខែឧសភានេះ បានសំរេចបង្កើតភ្នាក់ងារអនាម័យតាមសង្កាត់ ។

មន្ទីរបរិស្ថានរាជធានីភ្នំពេញបានឲ្យដឹងថា ភ្នាក់ងារនេះមានមុខងារផ្សព្វផ្សាយព័ត៌មាន លិខិតបទដ្ឋាន និង ត្រួតពិនិត្យការបញ្ចេញសំរាមរបស់ប្រជាពលរដ្ឋតាមដានការប្រមូលដឹកជញ្ជូនសំរាម របស់ក្រុមហ៊ុនស៊ិនទ្រី ។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងមួយសង្កាត់គឺមានពី២ទៅ៣នាក់ តាមទំហំរបស់សង្កាត់ ដោយដំណាក់ដំបូង គឺជ្រើសរើសចំនួន១២ សង្កាត់នៅក្នុងខណ្ឌចំការមន ធ្វើការសាកល្បងរយៈពេល១ ខែ មិថុនា ២០១៥ ។ បន្ទាប់ពីនោះ នឹងមានសិក្ខាសាលាដកពិសោធ ដើម្បីពង្រីកតំបន់អនុវត្តខណ្ឌទាំង០៤ ក្នុងក្រុង និងជាបន្តបន្ទាប់អនុវត្តទូទាំង ៩៦សង្កាត់ ។

រហូតមកដល់ពេលនេះ សំរាមត្រូវបានគេដឹងថា គឺជាកង្វល់មួយនិងជាបញ្ហាសង្គមមួយ ដែលសាលារាជធានីភ្នំពេញ នៅមិនទាន់ដោះស្រាយបាននៅឡើយ ជាពិសេសគឺការកកស្ទះសំរាម ការបោះចោលសំរាមនៅតាមផ្លូវ និងបញ្ហាផ្សេងៗ ។

សំរាមនៅរាជធានីភ្នំពេញ នៅពេលបច្ចុប្បន្ន ត្រូវបានគេប៉ាន់ប្រមាណថា មានបរិមាណប្រមាណជា ពី ១.៥០០ តោនទៅ ១.៧០០ តោន ហើយអាចលើសពីនេះផងក៏មាន ៕

## អាកាសធាតុក្តៅសម្លាប់មនុស្សជាង១០០០នាក់ស្លាប់នៅឥណ្ឌា

ក្រុមមន្ត្រីឥណ្ឌា បានប្រាប់ទីភ្នាក់ងារសារព័ត៌មានបារាំង AFPកាលពីចុងខែឧសភាថា អាកាសធាតុក្តៅខ្លាំងបានសម្លាប់មនុស្សជាង ១០០០ នាក់។

ប្រភពដដែលបានរាយការណ៍ថា ការស្លាប់នេះ គឺដោយសារតែរលកកំដៅកើនឡើងខ្លាំង ហើយអូសបន្លាយពេលវេលាយូរ ដោយពេលខ្លះសីតុណ្ហភាព បានឡើងដល់ ៥០ អង្សាសេនៅតំបន់ខ្លះ។

ក្រុមមន្ត្រីឥណ្ឌាបានព្រមានថា ចំ-នួនមនុស្សស្លាប់ អាចកើនឡើងដោយសារតួលេខជនរងគ្រោះនៅកំពុងត្រូវគេប្រមូលបន្ថែមមកទៀត ដោយសារតែ នៅរដ្ឋមួយចំនួនដូចជា រដ្ឋតេ-ឡានហ្គាណា នៅភាគខាងត្បូងប្រទេស កំពុងតែបន្តរងគ្រោះនឹងការវាយប្រហារដោយកំដៅនៅតែបន្ត។

ផ្នែកធំៗនៃប្រទេសឥណ្ឌា រួមមានរដ្ឋធានីញូវដេល្លី រងកំដៅចង់ឆេះអស់ពេលជាច្រើនថ្ងៃ ជាហេតុនាំឲ្យមានការភ័យខ្លាច អំពីការដាច់ចរន្តអគ្គិ-សនី។

សីតុណ្ហភាពខ្ពស់បំផុត ត្រូវបានគេកត់ត្រាឃើញ នៅរដ្ឋតេឡាន-ហ្គាណា និងរដ្ឋអាន់ដ្រាប្រាដេសក្បែរខាងនោះ។

អាជ្ញាធររដ្ឋ អាន់ ដ្រាប្រាដេស កំពុងអំពាវនាវឲ្យពលករ និង អ្នកដទៃទៀតកុំធ្វើការ ក្រោមកំដៅថ្ងៃយូរម៉ោងក្រោយពីមនុស្ស ១០០០នាក់ បានស្លាប់ ដោយសីតុណ្ហភាពឡើងខ្ពស់នៅទីនោះកាលពីសប្តាហ៍មុន។

ស្នងការពិសេស នៃនាយកដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ របស់រដ្ឋអាន់ ដ្រាប្រាដេស បានប្រាប់ទីភ្នាក់ងារសារព័ត៌មានAFPថា "ជនរងគ្រោះភាគច្រើន ជាអ្នករងកំដៅថ្ងៃផ្ទាល់ ដែលតាមធម្មតាមានអាយុចាប់ពី៥០ឆ្នាំ និងមកពីវណ្ណៈកម្មករ "។

## បីខែដើមឆ្នាំ ទីផ្សារនាំចេញផលិតផល ឧស្សាហកម្មកាត់ដេរធំជាងគេ របស់កម្ពុជាគឺអឺរ៉ុប

រយៈពេលបីខែ ដើមឆ្នាំ ២០១៥ នេះ ទីផ្សារនាំចេញទំនិញផលិតផលឧស្សាហកម្មកាត់ដេរធំជាងគេ គឺសហគមន៍អឺរ៉ុប ។

ក្រសួងពាណិជ្ជកម្ម បានឲ្យដឹងថា នៅក្នុងរយៈពេលមួយត្រីមាសទីមួយ ដើមឆ្នាំ ២០១៥ នេះកម្ពុជានាំចេញផលិតផល ឧស្សាហកម្មកាត់ដេរ សរុបប្រមាណជា១,៧៣ ពាន់លានដុល្លារ កើនឡើង១១ភាគរយ ធៀបនឹង ១,៥៦ពាន់លានដុល្លារ នៅក្នុងរយៈពេលដដែលកាលពីឆ្នាំ២០១៤ ។

ប្រភពដដែលបានឲ្យដឹងថា នៅក្នុងនោះ គឺនាំចេញទៅអឺរ៉ុប គឺមានតម្លៃ ៦៨០ លានដុល្លារ កើនឡើង ១៦ភាគរយ ទៅអាមេរិកជាគោលដៅទីពីរ គឺមានតម្លៃ ៥៣៧ លានដុល្លារ កើនឡើង១ភាគរយ ទៅប្រទេសផ្សេងៗ គឺមានតម្លៃ ៥២១ លានដុល្លារ ។

សព្វថ្ងៃនេះសហភាពអឺរ៉ុប គឺជាទីផ្សារផលិតផល នាំចេញរបស់កម្ពុជាធំជាងគេ ដោយក្រៅពីផលិតផលឧស្សាហកម្មកាត់ដេរ ដែលមាន បរិមាណប្រមាណជា ៨០ ភាគរយនៃផលិតផលនាំចេញសរុបរបស់កម្ពុជា ផលិតផលកសិកម្មមួយចំនួន ជាពិសេស គឺអង្ករ ម្រេចជាដើម ក៏ជាទីផ្សារធំជាងគេផងដែរនៅសហភាពអឺរ៉ុប៕

## រាជរដ្ឋាភិបាលកម្ពុជាយល់ព្រមជាគោលការទទួលជ័យលាភីជនពិការ៦នាក់ជាមន្ត្រី

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកាលពីចុងខែ ឧសភា បានប្រកាសថា ចំពោះជ័យលាភីទាំង៦រូប រាជរដ្ឋា-ភិបាលបានផ្តល់ជាគោលការណ៍ នូវក្របខណ្ឌដល់ជ័យលាភីទាំង ៦រូប ឱ្យបម្រើការងារនៅក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។

សម្តេចតេជោ ហ៊ុន សែន បានប្រកាសបែបនេះនៅពេល សម្តេចជួបសំណេះសំណាលជាមួយ ជ័យលាភី ពីកម្មវិធីប្រកួតបច្ចេកវិទ្យាព័ត៌មានពិការភាពនៅកូរ៉េ កាលពីពេលថ្មីៗ។

លោក អ៊ាង សុផល្លែត ជំនួយការសម្តេចតេជោ បានប្រាប់អ្នកយកព័ត៌មានបន្ទាប់ពីជំនួបថា សម្តេចតេជោ ហ៊ុន សែន សំដែងការកោតសរសើរពួកគេ ហើយមានប្រសាសន៍ថា នេះជាមោទនភាពណាស់ ចំពោះកម្ពុជាយើងដែល បេក្ខជនកម្ពុជាចូលរួមប្រកួតទាំង៦នាក់ បានទទួលមេដាយមាសទាំង៦ និងមេដាយមាសជើងឯកទៀតផង។

សម្តេចតេជោ ហ៊ុន សែន បានបន្តថា ជ័យលាភីទាំង៦ គឺពិការតែរាងកាយ តែមិនពិការចិត្តទេ គឺមានភាពឈ្លាសវៃ។ នៅក្នុងពិធីសំណេះសំណាលនេះដែរ សម្តេចតេជោ ក៏បានឧបត្ថម្ភថវិកាផ្ទាល់ របស់សម្តេចដល់ជ័យលាភីទាំង៦រូប ដោយក្នុងម្នាក់ៗទទួលបាន៣០០០ដុល្លារ។

រាជរដ្ឋាភិបាលកម្ពុជា កំពុងតែយកចិត្តទុកដាក់លើជនពិការ ដោយកាលពីពេលកន្លងទៅរាជរដ្ឋាភិបាលកម្ពុជា ក៏បានប្រកាសឲ្យក្រសួងនិងស្ថាប័នជាតិនានា ឲ្យជ្រើសរើសជនពិការចូលបំរើការងារផង៕

# គឹម យ៉េន "រាងកាយខ្ញុំទ្រុឌទ្រោមតែជំនឿរបស់ខ្ញុំមិនទ្រុឌទ្រោមទេ !"



ដូនចាស់គឹម យ៉េនអង្គុយក្រោមផ្ទះ

ដំណើរកោងៗញ័រៗ អមដោយឈើច្រត់មួយផង ដូនចាស់យើងខំប្រឹងឱនរើសសំរាម និងបោសសម្អាតទីធ្លា ព្រះវិហារជាមួយយុវជនមួយចំនួនផង ទោះបីជាដូនចាស់ពិបាកងើបក្រោកក៏ដោយ។ ក្មេងចាស់ប្រុសស្រីនៅក្នុងតំបន់ ដែលគាត់រស់នៅក្នុងភូមិទ្រាល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំនេះ តែងសរសើរអំពីកិច្ចការនិងជំនឿរបស់គាត់លើព្រះជាម្ចាស់។

ដូនចាស់រូបនេះឈ្មោះ គឹម យ៉េន អាយុប្រមាណ១០៤ឆ្នាំ ជាគ្រីស្តបរិស័ទកាតូលិក ដែលធ្លាប់ឆ្លងកាត់សម័យសំបូរសប្បាយ និងសង្គ្រាមរាប់មិនអស់ក្នុងជីវិតរបស់គាត់។ សំដីខ្សាវៗ ស្បែកជ្រីវជ្រួញ ភ្លេចភ្លាំងច្រើនផង យាយយ៉េនបានបន្លឺសំដីថា "ខ្លួនខ្ញុំចាស់មែន ទ្រុឌទ្រោមមែន តែខ្ញុំមានជំនឿរឹងមាំខ្លាំងណាស់ទៅលើសាសនាកាតូលិក ក្នុងព្រះនាមព្រះយេស៊ូ និងព្រះវរមាតាម៉ារី" ។

ដូនយ៉េនបានផ្លាស់ប្តូរជំនឿពីពុទ្ធបរិស័ទ មកជាគ្រីស្តបរិស័ទវិញក្នុងអំឡុងទសវត្ស ៧០ ដែលជាពេលដែលកម្ពុជាមានសង្គ្រាមស៊ីវិល និងរងផលប៉ះពាល់ ពីសង្គ្រាមបរទេសផង។ ដូនចាស់រូបនេះបានរក្សាជំនឿរបស់ខ្លួនរហូតមកដល់សព្វថ្ងៃនេះ ។ ទោះជាវ័យជរា និងរាងកាយមិនមាំមួនដូចក្មេងក៏ដោយក៏ដូនចាស់យ៉េនមិនដែលភ្លេចជំនឿរបស់ខ្លួនឡើយ។ ដូនយ៉េន "អត់ចាំឆ្នាំទេកូន (ជ្រមុជទឹក)។ ខ្ញុំកើតឆ្នាំអីក៏អត់ដឹងដែរ។តែធម៌ក្នុងវិហារខ្ញុំអត់ភ្លេចទេ។ ខ្ញុំសូត្រចាំតាំងពីក្មេង"។

ក្នុងអំឡុងពេលវឹកវរក្នុង សង្គ្រាមនោះ ដូនយ៉េនតែងតែអធិដ្ឋានជារៀងរាល់ពេល។ យាយបានឲ្យដឹងថា គាត់បានទទួលជ្រមុជទឹក ដោយលួចលាក់ ស្របពេលដែលកំពុងសាងសង់ព្រះវិហារថ្មីនៅក្តុលលើ ហើយគាត់រួមជាមួយគ្រីស្តបរិស័ទ ៤ ឬ ៥ នាក់ប៉ុណ្ណោះ បានរួមគ្នាអធិដ្ឋានជារៀងរាល់ថ្ងៃ។

ក្នុងសម្លៀកបំពាក់អាវកមូល ដៃបំពង់វែង មានហោប៉ៅសងខាងផង យាយយ៉េនស្លៀកសារ៉ុង អង្គុយនៅក្រោមផ្ទះរបស់ខ្លួន ដើម្បីស្វាគមន៍ភ្ញៀវ។ នៅលើផ្ទះរបស់របរចាស់ៗ និងសម្ភារនានាបានរៀបចំយ៉ាងមានសណ្តាប់ធ្នាប់។ យាយយ៉េនបានហៅភ្ញៀវឲ្យអង្គុយចុះ យកទឹកមកបំរើភ្ញៀវ ទាំងដំណើរពពីមពពើម ព្រោះភ្នែកគាត់ងងឹតហើយ។ ដូនចាស់ស្រដីថា "សព្វថ្ងៃរស់នៅម្នាក់ឯង ដាំបាយធ្វើម្ហូប។ ពេលឈឺតែម្នាក់ឯង"។

ទោះបីបច្ចុប្បន្ន យើងមើលទៅគាត់ហាក់ដូចជាពិបាក យ៉ាងណាក្តីប៉ុន្តែដូនយ៉េន ហាក់ពេញចិត្តនឹងជីវិតរបស់គាត់ ដែលប្រកបដោយព្រះពរពីព្រះជាម្ចាស់ ហើយគាត់ក៏មិនដែលត្អូញត្អែរពីការលំបាកទាំងនេះឡើយ ។ យាយប្រាប់ទៀតថា ការអធិដ្ឋានសំខាន់ណាស់ក្នុងជីវិតជាគ្រីស្តបរិស័ទរបស់គាត់ ហើយព្រះពររបស់ព្រះជាម្ចាស់តែងតែបង្ហូរមក ដោយការសុំអង្វរប្រកបដោយជំនឿ។ ដូនយ៉េន "ដោយសារជំនឿ ខ្ញុំអាចរស់នៅបានដោយខ្លួនឯង។ ពេលខ្លះខ្ញុំគ្មានអាហារហូប តែខ្ញុំអធិដ្ឋានសុំអង្វរព្រះវរមាតា។ ស្អែកឡើងមានអ្នកចិត្តធម៌យកបាយសម្លរមកឲ្យហូប។ ឈឺថ្កាត់ពេលយប់អីនៅម្នាក់ឯង ចេះតែអធិដ្ឋានអង្វរព្រះជាម្ចាស់។ ហើយព្រះអង្គ តែងតែស្តាប់នូវសេចក្តីត្រូវការរបស់ខ្ញុំ"។

លោកយាយគឹម យ៉េន មានកូនចំនួន៥នាក់ និងមានចៅៗជាច្រើនផងដែរ ដែលភាគច្រើនជាកសិករក្រីក្រ។ យាយបានឲ្យដឹងថា កូនចៅរបស់យាយពេលរៀបការរួចពួកគាត់បានទៅតាមខេត្តនានា និងខ្លះក៏នៅក្បែរផ្ទះយាយ និងខ្លះក៏បានស្លាប់ទៅហើយ។ និយាយពីជំនឿកូនចៅដូនចាស់យ៉េន ហាក់ដូចជាមិនសូវសប្បាយចិត្តសោះ។ លោកយាយឲ្យដឹងថា កូនចៅគេតាមគ្រួសាររបស់គេ ទោះខំនិយាយអប់រំឲ្យទៅព្រះវិហារក៏គេមិនស្តាប់ដែរ គេធំហើយគេមានសេរីភាពដើម្បីសម្រេចចិត្ត។ កូនចៅរបស់យាយពេលខ្លះ ពួកគាត់មកសួរសុខទុក្ខ និងជូនម្ហូបអាហារដល់យាយផងដែរ។

សព្វថ្ងៃដូនចាស់យ៉េន ធ្វើដំណើរទៅព្រះវិហារដោយខ្លួនឯង ហើយតែងតែមានសកម្មភាពជានិច្ចនៅក្នុងព្រះវិហារ។ លោក បូល្លេលី លូកា ជាបូជាចារ្យ ទទួលខុសត្រូវនៅព្រះសហគមន៍កាតូលិកក្តុលលើ បានប្រាប់ឲ្យដឹងថា គ្រប់ពេលវេលាលោកតែងតែឃើញលោកយាយ មានសភាពរឹងមាំជានិច្ច ទោះបីជាពេលខ្លះ លោកយាយមានការឈឺថ្កាត់បន្តិចក៏ដោយ ក៏លោកយាយតស៊ូធ្វើដំណើរមកព្រះវិហារ ជារៀងរាល់ថ្ងៃអាទិត្យ ឬពេលដែលមានកម្មវិធីបុណ្យផ្សេងៗ។

លោកបូជាចារ្យរូបនេះបន្តថា "អ្វីដែលពិសេសនោះ គឺពេលដែលលោកយាយមកដល់ព្រះវិហារ គឺគាត់តែងតែសម្អាតព្រះវិហារ រើសស្លឹកឈើនិងសំរាមផ្សេងៗស្ទើរគ្រប់ពេល។ លោកយាយបានបង្ហាញពីជំនឿ និងផ្តល់គំរូជាច្រើនទៅដល់គ្រីស្តបរិស័ទ ។ នេះជាសក្ខីភាព មួយយ៉ាងពិសេសណាស់ សម្រាប់គ្រីស្តបរិស័ទគ្រប់រូប និងសម្រាប់ក្មេងជំនាន់ក្រោយៗ"។

ក្នុងកិច្ចសន្ទនា លោកយាយយ៉េន បានលើកឡើងថា ជីវិតគាត់ពឹងផ្អែកទាំងស្រុងលើព្រះជាម្ចាស់ ហើយគាត់នឹងតស៊ូរស់នៅក្នុងជីវិតនេះ ដោយផ្តល់សក្ខីភាពអំពីព្រះជាម្ចាស់ ដល់យុវជនជំនាន់ក្រោយ។ លោកយាយបានផ្តាំឲ្យអស់បងប្អូន ជាគ្រីស្តបរិស័ទទាំងអស់ "សូមស្រលាញ់ព្រះជាម្ចាស់ ស្រលាញ់បងប្អូន និងស្រលាញ់ព្រះសហគមន៍ និងសូមឲ្យមានជំនឿរឹងមាំ ដើម្បីបន្តជំនឿនេះទៅដល់ក្មេងជំនាន់ក្រោយ ព្រោះថាបើទោះបីជាយើងស្លាប់ទៅ ក៏នៅមានក្មេងជំនាន់ក្រោយបន្តជំនឿដែរ"។

**ដោយរឿន ស្រីម៉ាច**

## សន្ត ម៉ាស៊ីមីលីយ៉ាំង កូលបេ

លោក ម៉ាស៊ីមីលីយ៉ាំង កូលបេ កើតនៅឆ្នាំ ១៨៩៤ នៅប្រទេសប៉ូឡូញ។កាលពីនៅក្មេងលោកយល់សប្តិឃើញព្រះនាង ម៉ារី បង្ហាញផ្កាកុលាបពណ៌សមួយទង និង ពណ៌ក្រហមមួយទងទៀតមកលោកទាំងសួរថា៖ តើកូនចង់បាន ផ្កាកុលាបណាមួយ?។ ម៉ាស៊ីមីលីយ៉ាំង បានឆ្លើយតបថា ចង់បានទាំងពីរតែម្តង។

ក្រោយមក ម៉ាស៊ីមីលីយ៉ាំងចូលបួសនៅក្រុមគ្រួសារសន្ត ហ្វ្រង់ស្វ័រនៅទីក្រុងអាស៊ីស៊ី។ លោកទៅប្រទេសជប៉ុនក្នុងបេសកកម្មផ្សាយលទ្ធិគ្រីស្តសាសនាតាមរយៈការបោះពុម្ពផ្សាយកាសែតជាច្រើន។ ក្រោយមកលោកត្រឡប់មកប្រទេសប៉ូឡូញវិញ នៅឆ្នាំ១៩៣៩។ នៅសម័យនោះ មានសង្គ្រាមលោកលើកទីពីរ។ លោកម៉ាស៊ីមីលីយ៉ាំង ត្រូវគេកៀរទៅដាក់នៅក្នុងជំរំប្រល័យពូជសាសន៍ ជនជាតិយូដា និង អស់អ្នកនយោបាយប្រឆាំងនឹងពួកផ្តុលនិយមអ៊ីត្លែរ។

នៅឆ្នាំ ១៩៤១ នៅក្នុងមន្ទីរឃុំឃាំង មានអ្នកទោសម្នាក់លួចរត់ចេញ។ មេបញ្ជាការមន្ទីរឃុំឃាំងខឹងយ៉ាងខ្លាំង ហើយជ្រើសរើសយកអ្នកទោសដប់នាក់ទៅសម្លាប់ ដើម្បីសងសឹក។នៅក្នុងចំណោមដប់នាក់នោះ មានបុរសម្នាក់ដែលមានគ្រួសារ និងកូនពីរនាក់។ បុរសនោះទ្រហោយំយ៉ាងខ្លាំង និងរៀបរាប់ថា៖ "ខ្ញុំស្លាប់ហើយ ខ្ញុំនឹងមិនបានជួបមុខប្រពន្ធនិង កូនជាទីស្រឡាញ់របស់ខ្ញុំទៀតទេ"។ ដោយឮដូច្នេះ ម៉ាស៊ីមីលីយ៉ាំង ក៏ស្ម័គ្រចិត្ត ទទួលទារុណកម្មដល់ស្លាប់ជំនួសបុរសនោះ។

ពីរអាទិត្យក្រោយមក ម៉ាស៊ីមីលីយ៉ាំង ក៏ទទួលមរណភាពទៅ។ តាមពិតទៅផ្កាកុលាបពណ៌ស បង្ហាញថា




ម៉ាស៊ីមីលីយ៉ាំងជាសន្តបុគ្គលម្នាក់ ឯផ្កាកុលាបពណ៌ក្រហមវិញ បង្ហាញថា លោកជាមរណសាក្សី៕

# ទិវានៃការត្រាស់ហៅសកលលើកទី៥២



*បងស្រីសុភី ចែកបទពិសោធន៍អំពីការត្រាស់ហៅដល់យុវជនយុវនារី ។ រូបថតៈសុធីរិទ្ធិ*

ព្រះសហគមន៍ កាតូលិកកម្ពុជា បានប្រារព្ធទិវា នៃការត្រាស់ហៅដូចព្រះសហគមន៍កាតូលិកទូទាំងសកលលោក ដែលធ្វើឡើង នៅមណ្ឌលសកម្មភាពភ្នំពេញថ្មី ក្នុងភូមិច្រេសសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខភ្នំពេញ ក្រោមអធិបតីភាពលោកអភិបាលភូមិភាគភ្នំពេញ អូលីវីយេ ឆ្មឹតអីស្លែរ និងមានអ្នកចូលរួមដែលជាក្រុមអេម៉ាណូអែល សាម៉ូអែល និងយុវជនយុវនារី មកពីភូមិភាគទាំងបីនៃ ព្រះសហគមន៍កាតូលិកចំនួនជិត ៣០០នាក់ កាលពីថ្ងៃទី២៥ និង២៦ មេសា ២០១៥។

ក្នុងថ្ងៃទីមួយនេះ លោកអភិបាល អូលីវីយេ បានអប់រំដល់ក្រុមយុវជនយុវនារីទាំងនេះឲ្យចេះស្តាប់ព្រះបន្ទូលត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយយកពេលវេលាស្ងៀមស្ងាត់ ដើម្បីស្តាប់ព្រះសូរសៀង និងលើកទឹកចិត្តពួកគេឲ្យជំនះនូវឧបសគ្គទាំងនៅក្នុងសង្គម ក្នុងក្រុមគ្រួសារ និងក្នុងខ្លួនយើងផ្ទាល់។

លោកក៏បានបន្តបង្ហាញ ពីគោលដៅនៃការត្រាស់ហៅ គឺចេញទៅជួបមនុស្សឯទៀត ដើម្បីប្រកាសដំណឹងល្អពីព្រះជាម្ចាស់និងយកចិត្តទុកដាក់ចំពោះអ្នកខ្វះខាតទាំងឡាយ គឺទាំងទ្រព្យសម្បត្តិ សីលធម៌ និងវិញ្ញាណ ហើយជួយអ្នកទាំងនោះ ឲ្យងើបឡើងវិញ។

ជាពិសេស លោកអភិបាល បានបន្ថែមពីរបៀបនៃការឆ្លើយតបចំពោះការត្រាស់ហៅនេះគឺ៖ ត្រូវភ្ជាក់ខ្លួនដោយព្រះជាម្ចាស់ បានត្រាស់ហៅដោយទទួលព្រះបន្ទូលព្រះអង្គ ហើយដើរតាមរបៀបរស់នៅរបស់ព្រះយេស៊ូ និងអរព្រះគុណនូវរាល់គម្រោងការដ៏អស្ចារ្យរបស់ព្រះអង្គ ព្រមទាំងសុខចិត្តបូជាជីវិត សម្រាប់ព្រះជាម្ចាស់ដោយបម្រើអ្នកដទៃ។

លោកបូជាចារ្យថ្មី ផាន បូរី ជាបូជាចារ្យទើបនឹងតែងតាំង កាលពីចុងឆ្នាំ ២០១៤ បានមកផ្តល់សក្ខីភាពអំពីការត្រាស់ហៅរបស់ព្រះជាម្ចាស់ ។ លោកបានពន្យល់ថា ការត្រាស់ហៅអាចធ្វើទៅបាន គឺត្រូវមានឆន្ទៈ និងការតស៊ូពេញមួយជីវិត គឺ១)បុគ្គលម្នាក់ៗ មានសេរីភាពចេញពីចំណងនៃក្រុមគ្រួសារ ដោយមានឆន្ទៈផ្ទាល់ខ្លួន ដើម្បីនៅជាមួយព្រះជាម្ចាស់និងគ្មានការបង្ខិតបង្ខំ។ ២)បណ្តោយខ្លួនទៅតាមការត្រាស់ហៅ របស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ ៣)លីឈើឆ្កាងរបស់ខ្លួន ដើរតាមព្រះយេស៊ូ ទោះបីជាមានឧបសគ្គផ្សេងៗ តែធ្វើដំណើរដោយចិត្តក្លាហាន ទុកចិត្តលើព្រះជាម្ចាស់ លះបង់ចិត្តលោភលន់ និងតណ្ហា ។

លោក បូរី បន្ថែមថា "បើចង់ធ្វើជាបូជាចារ្យ ជាដូនជី គឺត្រូវស្រឡាញ់ព្រះសហគមន៍ និងមិនត្រូវខ្ជិលអធិដ្ឋាន និងចូលរួមអភិបូជានោះទេ"។ លោកបន្ត ដោយសុំឲ្យយុវជនទាំងនោះមានសង្ឃឹម ទោះបីជាស្ថិតក្នុងកំរិតចំណេះដឹងខុសគ្នា ឬស្ថានភាពទ្រព្យសម្បត្តិក៏ដោយ ព្រោះព្រះយេស៊ូបានត្រាស់ហៅលោកសិលា នៅពេលដែលគាត់អស់សង្ឃឹម៕

**ដោយដាលីស**

# មនុស្សចំរុះជាតិសាសន៍ ៣៨នាក់ ទទួលអគ្គសញ្ញាលាបថ្ងាស

បេក្ខជនបេក្ខនារីចំរុះជាតិសាសន៍ចំនួន ៣៨នាក់ បានទទួលអគ្គសញ្ញាលាបថ្ងាសក្នុងឱកាសបុណ្យ ព្រះវិញ្ញាណយាងមក កាលពីថ្ងៃ ទី ២៤ ខែឧសភា នៅព្រះសហគមន៍កាតូលិកសន្តយ៉ូសែបផ្សារតូចភ្នំពេញ ដែលមានលោកអូលីវីយេ ឆ្មឹតអីស្លែរ អភិបាលព្រះសហគមន៍កាតូលិកភ្នំពេញជាអធិបតី និងមានបងប្អូនគ្រីស្តបរិស័ទចូលរួម ចំនួនប្រមាណជា ១៥០០នាក់ មកពីសហគមន៍កាតូលិក និយាយភាសា ផ្សេងៗរួមមានកូរ៉េ បារាំង អង់គ្លេស និងខ្មែរ។ ពិធីបុណ្យប្រព្រឹត្តិទៅ ដោយប្រើភាសាផ្សេងៗចូលគ្នា ដើម្បីបញ្ជាក់ថា "ទាំងអស់គ្នាជាមហាគ្រួសារតែមួយ"។

តាមឯកសារអប់រំជំនឿ នៃព្រះសហគមន៍កាតូលិកបាននិយាយថា ៖ អ្នកដែលទទួលអគ្គសញ្ញាលាបថ្ងាសគឺអស់ អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹករួចហើយ។ អគ្គសញ្ញានេះគឺបញ្ជាក់បន្ថែមថា បងប្អូនជាគ្រីស្តបរិស័ទពេញលក្ខណៈ។ ព្រះជាម្ចាស់ត្រាស់ហៅបងប្អូន ឲ្យទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបញ្ជាក់ជំនឿរបស់ខ្លួននិងចាត់ឲ្យបងប្អូនចេញទៅប្រកាស ដំណឹងល្អអំពីជំនឿរបស់ខ្លួនធ្វើជាសាក្សី នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ ដល់មនុស្សឯទៀតៗ។

នៅក្នុងធម្មទេសនា លោកអភិបាលអូលីវីយេ បានមានប្រសាសន៍ដល់បងប្អូន ដែលទទួលអគ្គសញ្ញាលាបថ្ងាស ឲ្យរស់នៅស្របតាមព្រះវិញ្ញាណដ៏វិសុទ្ធ និងជាគ្រីស្តបរិស័ទដែលអនុវត្តតាមព្រះបន្ទូលព្រះយេស៊ូ។

លោកអភិបាលបន្តថា ចូររស់នៅឲ្យជាមួយព្រះយេស៊ូជានិច្ច មានចិត្តស្រឡាញ់កាន់តែខ្លាំងឡើងៗ ប្រកាសពីព្រះរាជ្យរបស់ព្រះជាម្ចាស់ ដើម្បីឲ្យអ្នកដទៃមានសេចក្តីសង្ឃឹម និងទទួលបានសេចក្តីស្រឡាញ់ សារជាថ្មី។ ប្រកាសដំណឹងល្អអំពី "ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ" នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។



*លោកអភិបាលលាបប្រេងគ្រីស្មាដល់បេក្ខជនលាបថ្ងាស។ រូបថតៈសម្បត្តិ*

លោកអភិបាល ក៏បានដាស់តឿនគ្រីស្តបរិស័ទ ឲ្យយកចិត្តទុកដាក់រស់នៅ រួមគ្នាជាធ្លុងតែមួយ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធ។ ចេះបង្កើតការសន្ទនារវាងគ្នា និង គ្នា។ ស្តាប់គ្នាទៅវិញទៅមក រវាងជាតិសាសន៍មួយ និងជាតិសាសន៍មួយផងដែរ ដើម្បីឲ្យយើងអាចរស់នៅ ដោយសន្តិភាព និងក្តីស្រឡាញ់ជាគ្រួសារតែមួយ។

យុវតី ពី ពិសី ជាបេក្ខនារីទើបតែទទួលអគ្គសញ្ញាលាបថ្ងាសរួច បាននិយាយថា៖ នាងបានទទួលការអប់រំជំនឿអស់រយៈពេល៥ឆ្នាំ ដើម្បីបានទទួលអគ្គសញ្ញាលាបថ្ងាសនេះ នាងយល់ថា ព្រះវិញ្ញាណដ៏វិសុទ្ធបានណែនាំនាងឲ្យស្គាល់សេចក្តីស្រឡាញ់និងកាតព្វកិច្ច ដែលជាគ្រីស្តបរិស័ទកាតូលិក ត្រូវធ្វើដោយចេះពិចារណានូវអ្វីដែលល្អ និងមិនល្អហើយកែប្រែចិត្តគំនិតក្នុងការរស់នៅ ឲ្យសមស្របជាបុត្រធីតារបស់ព្រះជាម្ចាស់ ព្រមទាំងព្យាយាម ប្រកាសជំនឿដល់មិត្តភ័ក្តដែលមិនទាន់ស្គាល់ ព្រះជាម្ចាស់ផងដែរ។

**ដោយដាលីស**

# មណ្ឌលស្នាក់នៅសិស្សណ្វូប៊ីលី ជួយដល់កុមារក្រីក្រទទួលបានការសិក្សា



*សិស្សស្នាក់នៅក្នុងមណ្ឌលណ្វូប៊ីលីបរិភោគអាហារពេលល្ងាចរួមគ្នា។*

កត្តាសាលារៀននៅឆ្ងាយ ឬគ្មានសាលារៀនគ្រួសារខ្វះលទ្ធភាពឲ្យកូនបន្តការសិក្សាបានធ្វើឲ្យកុមារ និងយុវជនជាច្រើន បានបោះបង់ការសិក្សា ហើយខ្លះបានចំណាកស្រុកទៅរកការងារធ្វើ។ ដោយសារហេតុនេះ ព្រះសហគមន៍កាតូលិក សន្ត ប្រ៊្សង់ស្វ័រ សាវីយ៉េបានបង្កើតមណ្ឌលស្នាក់នៅមួយ សម្រាប់សិស្សក្រីក្រដែលមកពីបណ្តាស្រុក និងខេត្តមួយចំនួនឲ្យបានសិក្សា និងទទួលបានឱកាសអប់រំដូចកុមារនិងយុវជនដទៃទៀតក្នុងសង្គម។

លោកបូជាចារ្យ ពូទី៉រាជេត ជាអ្នកទទួលខុសត្រូវ លើមណ្ឌលស្នាក់ណ្វូប៊ីលី បានមានប្រសាសន៍ថា មានកត្តាមួយចំនួនដែលបានជំរុញឲ្យព្រះសហគមន៍បង្កើត នូវមណ្ឌលស្នាក់នៅសិស្សនេះគឺ"ដោយសារកូនសិស្សនៅជនបទ គ្មានឱកាសទៅរៀននៅសាលារៀនល្អៗ ហើយភូមិខ្លះៗអត់មានសាលារៀនតែម្តង ជាពិសេសវិទ្យាល័យ បើមានក៏តិច ហើយឆ្ងាយដែរ។ សិស្សភាគច្រើន រៀនត្រឹមថ្នាក់ទី៦ ឬទី៩ប៉ុណ្ណោះ ព្រោះអត់សាលារៀន"។

មណ្ឌលសិស្ស ណ្វូប៊ីលី បានបង្កើតឡើង ក្នុងឆ្នាំ២០០៣ ដែលមានទីតាំង ស្ថិតនៅសង្កាត់កំពង់ស្វាយ ក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ។ សព្វថ្ងៃមានសិស្សសរុបចំនួន៤០នាក់ ដែលមានស្រីចំនួន ២៣នាក់ ហើយភាគច្រើនពួកគាត់ជាពុទ្ធបរិស័ទ។ សិស្សភាគច្រើន មកពីបន្ទាយមានជ័យ ហើយមានខ្លះមកពីបាត់ដំបង សៀមរាប និង ខេត្តកណ្តាល។

លោកបូជាចារ្យ ៉រាជេត បន្ថែមទៀតថា "គម្រោងរបស់យើង ទទួលសិស្សនៅថ្នាក់ទី១០-១១ និង១២។ ប្រសិនបើមានករណីពិសេស យើងក៏អាចទទួលដែរ ដូចជាក្មេងកំព្រា សិស្សដែលចង់រៀន មកពីគ្រួសារក្រីក្រមែនទែន យើងទទួលពួកគេដូចជាឆ្នាំនេះយើងមានថ្នាក់ទី៧ ដល់ទី៩ ដែរមានចំនួន៧នាក់"។

កំពុងអង្គុយរៀន ជាមួយមិត្តភក្តិ ពេក កុលាប ជាកូនគ្រីស្តបរិស័ទអាយុ ១៩ឆ្នាំ មកពីភូមិតាអំ នៃខេត្តបន្ទាយមានជ័យ បានមកស្នាក់នៅមណ្ឌលសិស្សនេះ រយៈពេល៣ឆ្នាំមកហើយ ដោយសារជីវភាពគ្រួសារលំបាក ធ្វើស្រែចំការបានផលតិចតួច មានកូនច្រើនក្នុងបន្ទុកដល់ទៅ៧នាក់ និងនៅតំបន់ដែលនាងរស់នៅ គ្មានសាលាវិទ្យាល័យនៅក្បែរផ្ទះ របស់គាត់ឡើយ តែមានចំងាយ២០ គីឡូម៉ែត្រឯណោះ។ កុលាប បានឲ្យដឹងថា "ដោយសារគ្រួសារខ្ញុំក្រ ខ្ញុំអត់មានលុយរៀនក្រៅ(រៀនគួរ)។ លោកគ្រូធន់ (អ្នកទទួលខុសត្រូវព្រះសហគមន៍កាតូលិកនៅភូមិតាអំ) បានបញ្ជូនខ្ញុំឲ្យមកនៅស្វាយ(ស៊ីសុផុន) នេះ ដើម្បីខ្ញុំបានរៀនតទៅទៀត"។

សព្វថ្ងៃនេះ កុលាបកំពុងសិក្សានៅថ្នាក់ទី១២។កុលាបបានឲ្យដឹងទៀតថា "នៅទីនេះ មានពេលវេលារៀនច្រើន ដោយយើងមិនបាច់ធ្វើការងារផ្ទះ ធ្វើស្រែចំការ និងគិតច្រើន។ នៅនេះយើងធ្វើការងារជាក្រុម មានទំនាក់ទំនងជាមួយគ្នា ហើយចេះស្រឡាញ់គ្នាយល់ចិត្តគ្នាទៅវិញទៅមក"។

ក្រៅពីការសិក្សា យុវជទាំងនោះ បានចូលរួមក្នុងការងារព្រះសហគមន៍ និងក្នុងសង្គម ដើម្បីជួយអ្នកក្រីក្រ អ្នកជំងឺ ជនពិការ និង ក្មេងកំព្រា ដោយបង្រៀនកុមារ និងធ្វើបបរចែកកុមារតាមភូមិ ចុះសួរសុខទុក្ខអ្នកក្រីក្រនៅតាមភូមិ និងអ្នកជំងឺនៅតាមមន្ទីរពេទ្យជាដើម សំអាតព្រះវិហារ ចូលរួមអប់រំជំនឿថ្ងៃអាទិត្យជាដើម។

និយាយពីអនាគត កុលាបបានឲ្យដឹងដែរថា "ខ្ញុំគិតចង់ធ្វើគ្រូបង្រៀន ដោយសារខ្ញុំចង់ឲ្យក្មេងគេមានសុជីវធម៌ល្អ ហើយដល់ពេលគេធំទៅ គេកាន់តែល្អទៀត"។

មិនសូវខុសគ្នា ពីយុវតីខាងលើទេ ផន សុផាន់ណា អាយុ១៥ឆ្នាំ មកពីស្រុកព្រះនេតព្រះ បាននិយាយថា "នៅខែវស្សា ផ្លូវពិបាក លិចទឹក អត់ដែលបានរៀនសូត្រអីទេ។ នៅទីនេះ (មណ្ឌល) បានរៀនច្រើន បានរៀនគួរបន្ថែម ព្រោះនៅផ្ទះអត់មានលុយរៀនទេ ហើយគ្រូបង្រៀនអត់សូវជិតដល់មួយខែមកតែ២ ឬ៣អាទិត្យ"។ យុវជនរូបនេះបន្ថែមថា នៅក្នុងមណ្ឌលពេលទំនេរ ទៅចំការព្រះសហគមន៍ធ្វើការងារតិចតួច ដើម្បីយកបទពិសោធន៍ ព្រោះពេលទៅផ្ទះវិញឆ្លៀតធ្វើការងារចំការខ្លះៗ ដែលធ្វើបាន។

យុវជនសុផាន់ណា ឲ្យដឹងទៀតថា ពេលរៀនចប់យុវជនរូបនេះ ចង់ក្លាយជាគ្រូបង្រៀនម្នាក់ ដើម្បីទៅបង្រៀនកុមារនៅក្នុងភូមិរបស់ខ្លួន ។ "ខ្ញុំចង់ធ្វើជាគ្រូបង្រៀន ដោយសារនៅស្រុកខ្ញុំអត់សូវមានអ្នករៀន មានអ្នកចង់រៀន តែគ្រូមិនសូវបង្រៀនសិស្ស ដោយយកចិត្តទុកដាក់ទេ។ ពេលខ្ញុំឃើញអីចឹង ខ្ញុំស្រណោះ ខ្ញុំចង់ជួយឲ្យគេមានអនាគតល្អ។ ភាគច្រើនភូមិខ្ញុំ ឈប់រៀនទៅថៃអស់ អត់មានណានៅផ្ទះទេ"។

លោកបូជាចារ្យបន្ថែមថា ក្នុង១ឆ្នាំ គ្រួសាររបស់សិស្សទាំងអស់ត្រូវបង់ប្រាក់ជូនមណ្ឌល ៣០ម៉ឺនរៀល និងអង្ករ១៥០គីឡូក្រាមសម្រាប់ការចំណាយលើការហូបចុក។ លោកបន្ថែមទៀតថា ប៉ុន្តែក៏មានករណីខ្លះមណ្ឌលបានលើកលែង ឬក៏ឲ្យបង់ប្រាក់តិចជាងនេះ ទៅតាមលទ្ធភាពនៃគ្រួសារនីមួយៗ។

លោកបូជាចារ្យ ៉រាជេត បានឲ្យដឹងដែរថា សិស្សវិទ្យាល័យយើងមានកម្មវិធីសិក្សាដល់ពួកគេ គឺក្នុងប៉ុន្មានឆ្នាំនេះ យើងបានជួលគ្រូ ពីខាងក្រៅដើម្បីមកបង្រៀនពួកគេមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យាជាដើម។ ហើយលទ្ធផលសម្រាប់ឆ្នាំទៅ គឺយើងបានសិស្ស៦នាក់ ជាប់បាក់ឌុប ក្នុងចំណោម៧នាក់។ កម្មវិធីនេះយើងនឹងមានបន្តទៀតទៅឆ្នាំក្រោយៗ ដើម្បីកសាងគុណភាពៃការសិក្សា ឲ្យបានល្អ សំរាប់យុវជននៅជនបទទាំងនេះ៕

**ដោយកញ្ញា**

## ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

**មាត្រា១៥** ៖នៅកន្លែងរថយន្ត ក្រុង (រថយន្តដឹកអ្នក ដំណើរសាធារណៈ ) ឈប់នៅក្នុងទីប្រជុំជន អ្នកបើកយាន្តជំនិះគ្រប់ប្រភេទ ត្រូវបន្ថយល្បឿន ហើយចាំបាច់ត្រូវឈប់ ដើម្បីទុកឲ្យរថយន្តក្រុងចេញចូល ឬឈប់បាន ដោយងាយស្រួល។

**មាត្រា២៣** ៖ ការឈប់ ឬចត

-នៅក្រៅទីប្រជុំជន គ្រប់យាន្តជំនិះដែលខូចគាំង ឬត្រូវបង្ខំឲ្យឈប់ ឬចតនៅលើទ្រូងផ្លូវ ត្រូវប្រើភ្លើងសញ្ញាអាសន្ន ឬដាក់សញ្ញាអាសន្ន ចម្ងាយយ៉ាងតិច ៣០(សាមសិប) ម៉ែត ដែលអាចមើលឃើញយ៉ាងតិច ១០០ (មួយរយ)ម៉ែត។ ក្នុងករណីបញ្ហាខាងលើនេះកើតឡើងនៅកន្លែងហាមឈប់ ឬចតត្រូវជូនដំណឹងដល់សមត្ថកិច្ចដែលនៅជិត ដើម្បីមានវិធានការបន្ថែម។

- នៅក្នុងទីប្រជុំជន គ្រប់យានជំនិះ ដែលត្រូវឈប់ ឬចតដាក់ទំនិញ ឬមនុស្សឡើងចុះ នៅមិនលើសពីចម្ងាយ២៥ (ម្ភៃប្រាំ) សង់ទីម៉ែតពីគែមចិញ្ចើមផ្លូវ និងយ៉ាងតិច៥ម៉ែតពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង និងចន្លោះយ៉ាងតិច១០ (ដប់)ម៉ែត ពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោងនៃមហាវិថី។ នៅទីប្រជុំជនយានជំនិះទាំងអស់ត្រូវឈប់ ឬចតយានជំនិះយ៉ាងតិចបំផុត១០ (ដប់)ម៉ែតពីផ្លូវប្រសព្វ ឬផ្លូវបត់ ឬផ្លូវកោង។

# យុវជនស្វែងរកវិធីសាស្ត្រដើម្បីទទួលបានភាពជោគជ័យ



*ក្រុមយុវជនផ្តល់វិធីសាស្ត្រសម្រាប់ភាពជោគជ័យ ។រូបថតៈ ស្រីម៉ាច*

ព្រះសហគមន៍ កាតូលិកភូមិភាគកំពង់ចាមបានរៀបចំកម្មវិធីសន្និបាតមួយដើម្បីលើកទឹកចិត្តយុវជនឲ្យចេះតស៊ូក្នុងជីវិតរស់នៅរបស់ខ្លួន និងរស់នៅប្រកបដោយជំនឿ លើព្រះជាម្ចាស់ កាលពីថ្ងៃទី ១៣ដល់១៥ ឧសភាកន្លងទៅ លើប្រធានបទជីវិតនៃភាពជោគជ័យ ដែលមានយុវជនប្រមាណ៨ ០នាក់ ចូលរួមធ្វើឡើង នៅព្រះសហគមន៍កាតូលិក ប៊ូស្រា ក្នុងខេត្តមណ្ឌលគិរី។

លោកអេមេល្យូដាល ហ្វ្រង់ស្វ័រ ជាបូជាចារ្យដឹកនាំ ក្រុមយុវជនមានប្រសាសន៍ថា កម្មវិធីសន្និបាតនេះមានទិសដៅចំនួន ២ គឺទីមួយព្រះសហគមន៍ ចង់លើកទឹកចិត្តយុវជនយុវនារីទាំងអស់ ឲ្យមានកម្លាំងតស៊ូជំនះ រាល់បញ្ហាដែលកើតមានចំពោះពួកគេ និងធ្វើឲ្យពួកគេមិនអាចទៅមុខឬមិនចង់បន្តដំណើរទៅមុខទៀតដូចជាការសិស្សា ស្នេហា និងបញ្ហាគ្រួសារជាដើម។ និងទី២ គឺចង់ឲ្យយុវជនចេះពឹងលើព្រះជាម្ចាស់ ពេលដែលពួកគាត់មានបញ្ហា គឺត្រូវអធិដ្ឋានស្តាប់អត្ថបទព្រះគម្ពីរ ទុកពេលវេលានៅស្ងៀមស្ងាត់ ដើម្បីរិះគិតពីបញ្ហាទាំងឡាយដែលកំពុងតែកើតមាន និងស្វែងរកអ្នកដែលយើងទុកចិត្ត ធ្វើជាទីប្រឹក្សាយោបល់។

លោកបូជាចារ្យបន្តទៀតថា សកម្មភាពទាំងនេះគឺជាជំហានមួយសម្រាប់យុវជនទាំងអស់ បង្កើតកម្លាំងចិត្តបន្តិចម្តងៗ ដើម្បីរំដោះខ្លួនចេញពីបញ្ហា និង អាចឈានទៅរកភាពជោគជ័យក្នុងជីវិតរបស់ពួកគេ។

យុវជន-យុវនារី ដែលចូលរួមក្នុងសន្និបាតនេះ មកពីប្រាំតំបន់នៃភូមិភាគកំពង់ចាម រួមមាន រតនគិរី ស្ទឹងត្រែង ក្រចេះ កំពង់ចាម និងមណ្ឌលគិរី។ កម្មវិធីសន្និបាតនេះបានរិះគិតជាក្រុមតូចៗ និងចែករំលែកបទពិសោធន៍ទៅវិញទៅមក រួមទាំងមាន ប្រធានបទតូចៗជាច្រើនទៀតដើម្បីស្រាយបំភ្លឺ និងផ្តល់ជាវិធីសាស្ត្រ ក្នុងការរកដំណោះស្រាយផ្សេងៗ ពេលជួបនូវឧបសគ្គក្នុងជីវិត។

បងស្រី ញឹប សុខនី បានធ្វើបទបង្ហាញមួយស្តី អំពីចំណុចសំខាន់ៗដើម្បីទទួលបានជោគជ័យក្នុងជីវិត។ បងស្រីមានប្រសាសន៍ថា ភាពជោគ-ជ័យគឺស្ថិតនៅលើប្រាំចំណុចសំខាន់ៗ គឺការតស៊ូ កែប្រែចិត្តគំនិត លើកលែងទោស ស្វែងរកពន្លឺ និងស្វែងរកកម្លាំងថ្មី។ បងស្រីពន្យល់ថា មនុស្សម្នាក់ៗគ្មានអ្នកណាដែលមិនធ្លាប់ជួបនូវការបរាជ័យនោះទេ ប៉ុន្តែសូមយុវជន-យុវនារីទាំងអស់ កុំអស់សង្ឃឹមក្នុងជីវិត។ ភាពជោគជ័យយ៉ាងពិតប្រាកដ គឺយើងត្រូវពឹងផ្អែកទៅលើកម្លាំងរបស់យើងផង និងព្រះជាម្ចាស់ផង។

**ដោយរឿន ស្រីម៉ាច**

# ព្រះសហគមន៍លើកទឹកចិត្តអ្នកជំងឺមហារីក

ព្រះសហគមន៍កាតូលិក បានរៀបចំកម្មវិធីសំណាក់ធម៌ អ្នកជំងឺមហារីក និងអ្នកជម្ងឺទូទៅដើម្បីលើកទឹកចិត្ត និងជំរុញក្តីសង្ឃឹមដល់អ្នកជំងឺទាំងនោះ តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលណែនាំដោយលោកបូជាចារ្យ វ៉ាលដារីស (Val-daris) បានធ្វើឡើង កាលពីថ្ងៃទី ២៩-៣០ ឧសភាកន្លងទៅ នៅព្រះសហគមន៍កោះរកា ស្ថិតក្នុងស្រុកកោះរកាខេត្តកំពង់ចាម។

លោកអន់តូនីសាមី ស៊ូសៃរាជ្យ ជាអភិបាល ទទួលខុសត្រូវព្រះសហគមន៍កាតូលិក ភូមិភាគកំពង់-ចាមមានប្រសាសន៍ថា សំណាក់ធម៌នេះរៀបចំឡើង ក្នុងគោលបំណងជួយលើកទឹកចិត្ត បង្ហាញធម៌មេត្តាករុណា និងសេចក្តីស្រលាញ់របស់ព្រះយេស៊ូ ដល់បងប្អូនដែលមានជំងឺផ្សេងៗជាពិសេស គឺអ្នកជំងឺមហារីកតែម្តង។លោកអភិបាលបានបន្តថា សំណាក់ធម៌នេះអាចជួយដល់អ្នកជំងឺទាំងនោះ ទទួលបាននូវកំលាំងថ្មីពីព្រះយេស៊ូ ដែលអាចធ្វើឲ្យ ផ្លូវវិញ្ញាណរបស់ពួកគាត់បានស្ងប់ចិត្ត រីករាយ និងយល់ថា ព្រះយេស៊ូ ពិតជាស្រ-លាញ់ និងគង់នៅ



ជាមួយពួកគេជានិច្ច។

អ្នកជំងឺមហារីកម្នាក់ បានឲ្យដឹងថា គាត់មានសង្ឃឹមក្នុងការរស់នៅ និង យកចិត្តទុកដាក់បំពេញកិច្ចការដែលគាត់មានឡើងវិញ និងជាពិសេសគឺបានធ្វើឲ្យគាត់យល់ថា ព្រះយេស៊ូពិតជានៅក្បែរគាត់ជានិច្ច។

កម្មវិធីនេះ មានអ្នកចូលរួមប្រ-មាណ៣០នាក់ ដែលភាគច្រើនជាអ្នកជំងឺដែលមកពីខេត្តនានា រួមមានសៀមរៀប កំពង់ចាម និងភ្នំពេញ ៕

**ដោយរ៉ាវី**

## កំណាព្យ

# គាំទ្រស្ត្រីដើម្បីរួមចំណែកក្នុងសង្គម

( **បទពាក្យ ៧** )

*និពន្ធដោយអ្នកស្រី ខុង ណាវី*

១- ស្ត្រីគ្រប់រូបតែងប្រាថ្នា  សូមសុខចិន្តាគ្រប់ៗគ្នា
មិនចង់បញ្ហារាល់វេលា  បំពេញការងារក្នុងសង្គម ។
២- ជួយលើកទឹកចិត្តដល់ស្ត្រី  ទោះការងារអ្វីក៏ឧត្តម
មិនថាការនោះតូចឬធំ  ស្ត្រីខិតខំបានសម្រេច ។
៣- តស៊ូព្យាយាមត្រៀមពុះពារ  បំពេញការងារភារៈកិច្ច
មិនបោះបង់ចោលឬបំភ្លេច  ប្រឹងប្រែងជានិច្ចគ្រប់កិច្ចការ ។
៤- មានភាពស្មោះត្រង់និងគិតគូរ  ស្ត្រីហ៊ានប្តូរស្រាយបញ្ហា
ដើម្បីជីវភាពក្នុងគ្រួសារ  ចូលរួមស្នេហាសង្គមជាតិ ។
៥- ត្រូវលើកកម្ពស់ព្រោះស្ត្រី  មាតាល្អក្រៃមិនដែលឃ្លាត
គឺជាឆ្អឹងខ្នងរបស់ជាតិ  រក្សាបុត្រទៀតទាំងប្រុសស្រី ។
៦- ចង់រួមចំណែកក្នុងសង្គម  គាំទ្រជាធំដល់ស្ត្រី
កុំឡើយមើលស្រាលមាក់ងាយស្ដី  ថាជាតិស្ត្រីគ្មានបានការ ។
៧- សូមជួយសម្លឹងមើលសព្វថ្ងៃ  លោកជាស្វាមីក្នុងគ្រួសារ
តើភរិយាលោកនោះយ៉ាងណា  សូមពិចារណាឲ្យបានល្អិត ។
៨- ស្ត្រីត្រូវការអ្នកគាំទ្រ  ស្មារតីជំហរជួយអាណិត
លើកស្ទួយស្ត្រីស្ដីពាក្យពិត  ជួយផ្តល់គំនិតយោបល់ល្អ ។
៩- ដូចបានចូលរួមក្នុងសង្គម  មួយចំណែកធំដោយស្មោះស
អ្នកសាងស្ថិតស្ថំអំពើល្អ  ព្រះប្រទានពរសុខសួស្តី ។

# ៦៨នាក់ទទួលអគ្គសញ្ញាលាបថ្ងាសនៅបាត់ដំបង



*បេក្ខជនទាំង៦៨នាក់ថតរូបអនុស្សាវរីយ៍ជាមួយលោកអភិបាលគីគេ លោកបូជាចារ្យម៉ាណុច និងបូជាចារ្យតូតែត។*
*រូបថត: ប៊ុនរឿន*

ក្នុងឱកាស ថ្ងៃបុណ្យព្រះវិញ្ញាណយាងមកនៅព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានរៀបចំអគ្គសញ្ញាលាបថ្ងាស ជូនគ្រីស្តបរិស័ទចំនួន៦៨នាក់ ដើម្បីឲ្យក្លាយជាគ្រីស្តបរិស័ទពេញទី ក្នុងព្រះសហគមន៍ កាលពីថ្ងៃទី២៤ ខែឧសភា កន្លងទៅ នៅព្រះវិហារព្រះជាម្ចាស់ លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ស្ថិតនៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ក្រោមអធិបតីភាពលោកហ្វីការេដូ អេនរីគេ ជាអភិបាល ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

ថ្លែងនៅក្នុងពិធីនោះ លោកអភិបាលបានមានប្រសាសន៍ថា នៅថ្ងៃនេះ បងប្អូនបានទទួលអគ្គសញ្ញាលាបថ្ងាស មានន័យថា បងប្អូនបានពេញលក្ខណៈជាគ្រីស្តបរិស័ទ ។

លោកអភិបាល បានពន្យល់ថា អគ្គសញ្ញាលាបថ្ងាស គឺអំណាចនៃឫទ្ធានុភាពរបស់ព្រះវិញ្ញាណ ដ៏វិសុទ្ធ ដែលជួយបំភ្លឺ និងពង្រឹងជំនឿរបស់យើង ដើម្បីជួយឲ្យយើងមានសេចក្តីក្លាហាន និងមានអំណាចដ៏ខ្លាំងក្លាដោយដូចជាទាហាន ដែលតស៊ូក្នុងការការពារជំនឿរបស់ខ្លួន ។

អ្នកដែលទទួលអគ្គសញ្ញា លាបថ្ងាស គឺជាគ្រីស្តបរិស័ទ ដែលបានទទួលអគ្គសញ្ញាជ្រមុជទឹករួច។ អគ្គសញ្ញានេះ ជាពិធីបំពេញបន្ថែមលើអគ្គសញ្ញាជ្រមុជទឹក។ បានសេចក្តីថាតាមពិធីបុណ្យការចាក់បង្ហូរនៃព្រះវិញ្ញាណដ៏វិសុទ្ធ ឲ្យបានពេញលេញជាផលនៃអគ្គសញ្ញាលាបថ្ងាស ដូចព្រះជាម្ចាស់ បានចាក់បង្ហូរព្រះវិញ្ញាណ ឲ្យក្រុមគ្រីស្តទូតនៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក (លិទ្ធិព្រះសហគមន៍ ១៣០២)។

លោកអភិបាល អេនរីគេ ក៏បានផ្តាំផ្ញើដល់បងប្អូនទាំង៦៨នាក់ ត្រូវចូលរួមក្នុងសកម្មភាព នៃកិច្ចការបំរើព្រះសហគមន៍ ទៅតាមក្រុមនីមួយៗ ពោលគឺរិះគិតចូលរួមកិច្ចការបំរើទៅតាមលទ្ធភាព និងទៅតាមព្រះអំណោយទានរបស់ព្រះជាម្ចាស់ដែលប្រទានឲ្យពួកគាត់ម្នាក់ៗដោយមិនចាំបាច់ មានការអញ្ជើញនោះឡើយ។ លោកអភិបាល "យើងអាចចូលរួមនៅក្នុងក្រុមអនុគណៈកម្មការទាំងនោះដូចជា អនុគណៈកម្មការសង្គហៈ អនុគណៈកម្មការពិធីបុណ្យ អនុគណៈកម្មការអប់រំជំនឿ រួមនិងក្រុមសកម្មភាពផ្សេងៗទៀត ក្នុងព្រះសហគមន៍ ដើម្បីរួមគ្នាកសាងព្រះសហគមន៍ឲ្យមានការរីកចម្រើន ក្នុងសេចក្តីស្រឡាញ់ និងតាមព្រះហឫទ័យមេត្តាករុណា របស់ព្រះជាម្ចាស់នោះផង"។

**ដោយឡុង សម្ផស្ស**

# និស្សិតរិះគិតអំពីផ្លូវវិញ្ញាណនិងការសម្តែងមេត្តាករុណា

មណ្ឌលនិស្សិត កាតូលិកកម្ពុជាបានរៀបចំ សិក្ខាសាលាមួយផ្តោតសំខាន់លើការសម្តែងធម៌មេត្តាករុណានៅក្នុងសង្គម ដែលធ្វើឡើងនៅព្រះសហគមន៍សៀមរាប កាលពីថ្ងៃទី១៤ ឧសភាកន្លងទៅ។

លោកហ្គេហ្វ៊ី ម៉ារីយ៉ូជាបូជាចារ្យទទួលខុសត្រូវ មណ្ឌលនិស្សិតកាតូលិកកម្ពុជា និងជាអ្នកណែនាំក្នុងសិក្ខាសាលាមានប្រសាសន៍ថា គោលដៅនៃកម្មវិធីនេះ គឺចង់ឲ្យនិស្សិតយល់ពីភាពខុសគ្នានៃពាក្យ ស្នេហាសេចក្តីស្រឡាញ់ អាណិត និងធម៌មេត្តាក្នុងជីវិតរបស់គេ។ ជាពិសេសលោកចង់ឲ្យនិស្សិត យល់ច្បាស់អំពីសេចក្តីស្រឡាញ់ របស់ព្រះជាម្ចាស់តាមព្រះគម្ពីរដែលបានចែងមក។



*យុវជនកាតូលិកបែងចែកជាក្រុមតូចៗរិះគិតអំពីជីវិតខាងវិញ្ញាណ។*
*រូបថត: Photo supply*

លោកបានបន្ថែមទៀតថា ក្នុងនាមជាគ្រីស្តបរិស័ទ ការសំដែងធម៌មេត្តាករុណាមានន័យថា ត្រូវតែស្រឡាញ់ព្រះជាម្ចាស់និងអ្នកទៃហើយត្រូវបង្កើតចេញជាសកម្មភាពដែលធ្វើឲ្យសេចក្តីស្រឡាញ់នេះមិនស្ថិតស្រពោន។

សិក្ខាសាលានេះមាននិស្សិតចូលរួមប្រមាណ៨០នាក់ដោយរិះគិតអំពីជីវិតខាងផ្លូវវិញ្ញាណនិងកិច្ចការដែលនិស្សិត អាចសម្តែងធម៌មេត្តាករុណានៅក្នុងសង្គមដល់អ្នកដទៃ គ្រួសារ និងខ្លួនឯងផ្ទាល់។ ក្នុងឱកាសនោះដែរនិស្សិតទាំងអស់ ក៏មានឱកាសទៅទស្សនាប្រាង្គប្រាសាទនានា នៅតំបន់សៀមរាបផងដែរ ដើម្បីសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែមទៀតអំពីប្រវត្តិសាស្ត្រ នៃប្រទេសរបស់ខ្លួន ៕

**ដោយសុខឃីម**

# អង្គការការីតាសបណ្តុះបណ្តាលយុវជនដោយផ្តល់ជំនាញខ្លី




រូបថតអនុស្សាវរីយ៍នៅក្នុងពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សជំនាន់ទី២២និង២៣របស់អង្គការការីតាសកម្ពុជា។

កម្មវិធីអភិវឌ្ឍន៍យុវជន នៃអង្គការការីតាសកម្ពុជា បានរៀបចំពិធីចែកវិញ្ញាបនបត្របញ្ជាក់ការសិក្សា ដល់សិស្សជំនាន់ទី២២ និង ២៣ ក្រោមអធិបតីភាពឯកឧត្តម គីម រិទ្ធី អភិបាលរង ខេត្តកណ្តាល និងលោកហ្វីការេដូ អេនរីគេ ជាប្រធានអង្គការការីតាសកម្ពុជា រួមនិងតំណាងស្ថាបនរដ្ឋ អង្គការដៃគូជាច្រើនរូបទៀត និងអ្នកចូលរួមប្រមាណជាង ៣០០នាក់កាលពីថ្ងៃទី៣០ ខែមេសា កន្លងទៅ នៅក្រុងតាខ្មៅ ខេត្តកណ្តាល។

អ្នកស្រីសារី ភីរម្យ ជាអ្នកទទួលខុសត្រូវកម្មវិធីអភិវឌ្ឍន៍យុវជន មានប្រសាសន៍ថា ទិសដៅសំខាន់នៃកម្មវិធីអភិវឌ្ឍន៍យុវជន គឺផ្តោតសំខាន់លើយុវជន ដែលគ្មានលទ្ធភាពរៀនបន្ត យុវជនដែលគ្មានជំនាញពិតប្រាកដ យុវជនបោះបង់ការសិក្សា យុវជនចំណាកស្រុក និងយុវជនងាយរងគ្រោះ។ អ្នកស្រី សារី ភីរម្យ "គឺអង្គការរបស់យើងគឺជាស្ពានដើម្បីឲ្យគាត់អាចឆ្លងទៅកាន់កន្លែងផ្សេងៗទៀត និងអាចរៀនបន្ត។ ហើយទិសដៅសំខាន់ គឺយើងចង់ផ្តល់ឱកាសដល់យុវជន ក្នុងការទទួលបានជំនាញបច្ចេកទេស ដើម្បីឲ្យពួកគាត់អាចមានលទ្ធភាពរកចំណូល មានទំនុកចិត្ត ស្គាល់ពីតួនាទីរបស់ខ្លួនទាំងក្នុងគ្រួសារ និងសង្គមជាតិ"។

អ្នកស្រី សារី ភីរម្យ បានបន្ថែមទៀតថា ក្រៅពីបង្រៀនជំនាញ អង្គការការីតាសកម្ពុជា មានបន្ថែមនូវគុណតម្លៃនៃការអប់រំ មានវគ្គតម្រង់ទិស ចំនួន២ខែមុនពេលរៀនជំនាញ ដែលមានដូចជា ការរស់នៅជាក្រុម សុជីវធម៌សីលធម៌របៀបទំនាក់ទំនង គុណតម្លៃជាមនុស្ស ការទទួលខុសត្រូវខ្លួនឯង...ជាដើម។

វគ្គបណ្តុះបណ្តាល ជំនាញទាំង ១១ រួមមានជំនាញក្នុងមណ្ឌល មានចំនួន៤គឺ រដ្ឋបាល និងគណនេយ្យ ហិរញ្ញវត្ថុកុំព្យូទ័រអភិវឌ្ឍន៍សហគមន៍ និងគំនូរ រីឯជំនាញតាមរោងជាង រួមមាន៧ជំនាញ គឺជួសជុលអេឡិចត្រូនិច និងទូរសព្ទដៃ សំអាងការ និងកាត់សក់ ជួសជុលរថយន្ត និងម៉ូតូ ជាងអគ្គិសនី គ្រប់គ្រងភោជនីយដ្ឋាន ជួសជុលម៉ាស៊ីនត្រជាក់ និងជួសជុលម៉ាស៊ីនដេរ។

អ្នកស្រីភីរម្យបានឲ្យដឹងថា ទន្ទឹមនិងការរៀនជំនាញវិជ្ជាជីវៈ ជាមួយការីតាស យុវជនត្រូវបានផ្តល់នូវសកម្មភាពជាច្រើនដូចជា ៖ សកម្មភាពសិល្បៈ និងកីឡា សកម្មភាពសហគមន៍ ដំណើរទស្សនកិច្ចសិក្សា វេទិការ និងសិក្ខាសាលាផ្សេងៗ និងយុវជនអាចចូលរួមសកម្មភាពសង្គម ដូចជា៖ ទិវាសិទ្ធិនារី ទិវាអនាម័យបរិស្ថាន ទិវាដាំកូនឈើ ទិវាប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ទិវាយុវជនអន្តរជាតិ ទិវាសិទ្ធិមនុស្សអន្តរជាតិ ជាដើម។

កញ្ញាថន ស្រីពេជ្រ អាយុ២១ឆ្នាំ បានឲ្យដឹងថា ក្រោយពីការសិក្សានៅទីនេះរយៈពេលមួយឆ្នាំ នាងអាចមានសមត្ថភាព ដើម្បីធ្វើការងារបាន។ នាងបានបញ្ចប់ការសិក្សាផ្នែកគណនេយ្យ នៅក្នុងកម្មវិធីអភិវឌ្ឍន៍យុវជន នៃអង្គការការីតាសកម្ពុជារយៈពេល២ឆ្នាំមកហើយ ដែលសព្វថ្ងៃ ស្រីពេជ្រកំពុងបម្រើការងារនៅក្នុងស្ថាបនឯកជនមួយក្នុងទីក្រុងភ្នំពេញ។ ស្រីពេជ្រ "ខ្ញុំគិតថារៀនវគ្គខ្លីឆាប់បានការងារធ្វើ ហើយបន្ទាប់មកអាចរៀនបន្តទៀតបាន។ ទោះបីជាគ្មានលុយ ក៏អាចរៀនបានដែរ។ ពេលរៀនចប់ អាចមានសមត្ថភាពចេះធ្វើការងារ។ ខ្ញុំដឹងគុណដល់អង្គការណាស់ ព្រោះគ្រួសារខ្ញុំគ្មានលទ្ធភាពដើម្បីឲ្យខ្ញុំបានរៀនខ្ពស់ដូចគេទេ។ ខ្ញុំមករៀននៅខេត្តកណ្តាលនេះគឺស្នាក់នៅជាមួយគ្រួសារ មីងជួយឲ្យរៀនខ្លះ ខាងគ្រួសារខ្លះ"។

ស្រីពេជ្របានរំឭកថា ការសិក្សានៅទីនេះ គឺមិនត្រឹមតែទទួលបានជំនាញមួយដើម្បីចិញ្ចឹមជីវិតទេ តែក៏មានចំណេះដឹងមូលដ្ឋាន ក្នុងការរស់នៅក្នុងសង្គមផងដែរ។ ស្រីពេជ្រឲ្យដឹងថា "គាត់(អង្គការ)បង្រៀនឲ្យយើងចេះសាមគ្គីគ្នា ឲ្យយើងចេះធ្វើការងារជាក្រុម ចេះគោរពពេលវេលាធ្វើការងារ កុំគិតតែរឿងប្រាក់ខែ ត្រូវចេះទទួលខុសត្រូវ..."។

ចំណែកយុវជន ស៊ុំ សំណាង អាយុ២៧ឆ្នាំ ជាអតីតសិស្សរៀនផ្នែកកាត់សក់បុរសបានឲ្យដឹងដែរថា"រៀនចប់៦ខែ ខ្ញុំទៅបើកហាងកាត់សក់តូចមួយនៅខេត្ត (ព្រះវិហារ) អាចរកលុយបានគួរសមដែរ ដើម្បីមើលជំងឺម្តាយ និងជួយប្អូនៗ"។ សំណាងបានឲ្យដឹងទៀតថា គាត់អាចរកប្រាក់បានពីពីរម៉ឺនរៀល ទៅដប់ម៉ឺនរៀលក្នុងមួយថ្ងៃ ហើយអាចឈានដល់ម្ភៃម៉ឺនក៏មានដែរ ក្នុងអំឡុងពេលបុណ្យទានធំៗ។ សំណាង "ពីដំបូងឡើយមិនសូវជាមានសង្ឃឹមនឹងមុខរបរនេះប៉ុន្មានទេ តែបន្ទាប់ពីបើកបាន ប៉ុន្មានខែឃើញថា វាគ្រាន់បើដែរ។ ម៉ែគាត់សប្បាយចិត្ត។ នៅតំបន់នោះ អត់សូវមានអ្នកចេះកាត់សក់ម៉ូដទេ ។ ពួកគាត់ (ជាងកាត់សក់) ភាគច្រើនអត់ចេះ ច្នៃម៉ូតឲ្យទាន់សម័យទេ ដូច្នេះហើយគេមករកតែខ្ញុំ ជាពិសេសយុវវ័យ ចាស់អីក៏មានដែរ"។

សំណាងបានសង្កត់ធ្ងន់ថា ជំនាញអ្វីក៏ដោយ ឲ្យតែខិតខំរៀននោះប្រាក់នឹងរត់មកតាមក្រោយ តែត្រូវចេះឲ្យប្រាកដទើបងាយស្រួលរកប្រាក់។

កម្មវិធីចែកវិញ្ញាបនបត្រនេះ បានប្រគល់ជូនយុវជន២ជំនាន់ គឺជំនាន់ទី២២ (ឆ្នាំ២០១៣) មានចំនួន ១៣០នាក់ ដែលមានស្រីចំនួន ៥១ នាក់ និងជំនាន់ទី២៣ (ឆ្នាំ២០១៤) មានចំនួន៨៩នាក់ ដែលមានស្រីចំនួន២៧នាក់។

កម្មវិធីអភិវឌ្ឍន៍យុវជន បានបង្កើតឡើងក្នុងឆ្នាំ១៩៩២ ហើយរហូតដល់ឆ្នាំ២០១៤អង្គការការីតាសបានបណ្តុះបណ្តាលយុវជន ចំនួន ២៥៤៥ នាក់ (ស្រី៦៦០នាក់) ដែលក្នុងនោះមានចំនួន ៧៩ភាគរយទទួលបានការងារធ្វើនៅតាមស្ថាបននានា។ យុវជនចំនួន ២៦នាក់ផ្សេងទៀតកំពុងរកការងារធ្វើ និងយុវជនចំនួន៤០ នាក់បានបង្កើតអាជីវកម្មខ្លួនឯង និង ២១ នាក់បន្តការសិក្សានៅមហាវិទ្យាល័យ ហើយ និង២៦នាក់ផ្សេងទៀត ដែលមានស្រី ៣ បានបោះបង់ការសិក្សា។ ក្រៅពីបណ្តុះបណ្តាលជំនាញអង្គការក៏មានអន្តេវាសិកដ្ឋាន ដើម្បីឲ្យយុវជនមកពីខេត្តនានាស្នាក់នៅផងដែរ ៕

**ដោយកញ្ញា**

# លោក មួង រស់ ៖ ខ្ញុំមានកម្លាំងពេលឃើញបងប្អូនជួបជុំគ្នា



*លោកបូជាចារ្យ មួង រស់ ជូនព្រះកាយគ្រីស្តបរិស័ទក្រោយតែងតាំងជាបូជាចារ្យ ។រូបថតៈ វ៉ាន់ សម្បត្តិ*

"ខ្ញុំមានកម្លាំង ពេលឃើញបងប្អូនជួបជុំគ្នា"។ នេះជាការបរិយាយមួយយ៉ាងខ្លី របស់លោកបូជាចារ្យ យ៉ូសែប មួង រស់។ លោកបូជាចារ្យរូបនេះបន្តថា៖វត្តមានបងប្អូនវាហាក់ដូចជាការលើកទឹកចិត្តមួយ ដែលផ្តល់កម្លាំងដល់លោក ក្នុងការបន្តមុខងារជាបូជាចារ្យ។

លោកបូជាចារ្យ យ៉ូសែប មួង រស់ ជាបូជាចារ្យជាតិខ្មែរ ដែលទើបទទួលអគ្គសញ្ញាតែងតាំង ជាបូជាចារ្យកាលពីខែធ្នូ ឆ្នាំ២០១៤ កន្លងទៅ។ លោកធ្លាប់បម្រើកិច្ចការមួយរយៈ នៅព្រះសហគមន៍កាតូលិកផ្សារតូច ពេលលោកជានិស្សិតទេវវិទ្យាល័យ។

លោកបូជាចារ្យ ប្រ៊ុយណូ កូសម៉ ជាអតីត នាយកទេវវិទ្យាល័យកម្ពុជា និងជាបូជាចារ្យ ទទួលខុសត្រូវព្រះសហគមន៍ផ្សារតូច បានថ្លែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាន នៃការថ្វាយអភិបូជាលើកដំបូងរបស់លោក មួង រស់នៅផ្សារតូច។

លោកក៏បានថ្លែងទៅកាន់បងប្អូនគ្រីស្តបរិស័ទ ដែលចូលរួមក្នុងពិធីនោះថា៖ លោកយ៉ូសែបមួង រស់ ដលែហានអញ្ជើញចូលរួមថ្វាយអភិបូជានាព្រឹកនេះជាមួយយើង ពិតជាមានអត្ថន័យពិតមែន។ ដូចដែលបងប្អូនបានដឹងហើយ តាំងពីប៉ុន្មានសតវត្សមកហើយ ដែលព្រះសហគមន៍កាតូលិកយើង បានប្រកាសដំណឹងល្អនៅស្រុកខ្មែរ គឺតាំងពីឆ្នាំ១៥៥៥។ យើងមានបូជាចារ្យមួយចំនួន តែបាត់បង់វិញដោយសារសង្គ្រាម។ ស្ថានភាពព្រះសហគមន៍សព្វថ្ងៃ មិនដូចពីមុន។ តាំងពីឆ្នាំ ១៩៩០ ប្រទេសកម្ពុជាយើងបានបើកទូលាយសេរីភាពខាងសាសនា ជាពិសេសសេរីភាពក្នុងការប្រកាសដំណឹងល្អ សារជាថ្មីយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ បានបន្តបង្ហាញសក្ខីភាព នៃជំនឿរបស់ខ្លួនឲ្យអ្នកដទៃ។ នាំឲ្យបងប្អូនមួយចំនួនចង់ទទួលពិធីជ្រមុជទឹក ចង់ស្គាល់ព្រះយេស៊ូ ។

លោកសង្កត់ធ្ងន់ថា៖ ដោយសារបងប្អូនបន្តអធិដ្ឋាន និងបន្តផ្តល់សក្ខីភាព នាំឲ្យមានយុវជនមួយចំនួនចង់ឆ្លើយតប តាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយបន្តបម្រើព្រះសហគមន៍ ក្នុងឋានៈជាបូជាចារ្យ ជាបងប្រុស និងជាបងស្រីជាដើម។

លោកក៏បានលើកទឹកចិត្ត គ្រីស្ត-បរិស័ទដោយលើកឡើងថា៖ ក្នុងជីវិតរបស់យើង ក្នុងគ្រួសាររបស់យើង នរណាក៏ដោយ តែងតែជួបប្រទះនូវឧបសគ្គផ្សេងៗ ក៏ប៉ុន្តែដូចសន្តប៉ូល ធ្លាប់មានប្រសាសន៍ថា ៖ សម្រាប់យើង អំណរសប្បាយ សេច-ក្តីសុខសាន្តខ្លាំងជាង! សុភមង្គលដែលយើងបានទទួលពីព្រះជាម្ចាស់ ខ្លាំងជាងឧបសគ្គឯទៀតៗ នេះជាជំនឿរបស់យើង សេចក្តីសង្ឃឹមរបស់យើងជាគ្រីស្តបរិស័ទ។

ក្រោយពីបានទទួល ពិធីតែងតាំងរួចហើយ លោកអភិបាលគីគេ ជាអភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានចាត់លោកឲ្យទទួលខុសត្រូវព្រះសហគមន៍កាតូលិកមួយកន្លែងគឺព្រះសហគមន៍សន្តប៉ូលនៅស្ទឹង ស្ថិតនៅភូមិព្រែកសំរោង ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។ ក្នុងមុខងារថ្មី លោកបូជាចារ្យរូប នេះបានសូមបងប្អូន គ្រីស្តបរិស័ទទាំងអស់ ឲ្យបន្តអធិដ្ឋានសម្រាប់រូបលោក ក៏ដូចជា បូជាចារ្យថ្មីៗផ្សេងទៀត។ លោកថាដែលបូជាចារ្យថ្មីៗ មិនសូវមានកម្លាំងប៉ុន្មានទេ ដូច្នេះសូមជួយអធិដ្ឋាន ដើម្បីឲ្យលោកមានកម្លាំង ក្នុងការបន្តបម្រើព្រះសហ-គមន៍៕

**ដោយឡុង សម្ផស្ស**

## កុមារទទួលការអប់រំអំពីអនាម័យ

ព្រះសហគមន៍មេមត់ រៀបចំកម្មវិធីទិវា សិទ្ធិកុមារអន្តរជាតិ កាលពីថ្ងៃទី១មិថុនា ដើម្បីឲ្យកុមារយល់ដឹងបន្ថែម អំពីអនាម័យខ្លួនប្រាណ ដែលមានកុមារប្រមាណជា ១៥០ នាក់ ស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។

អ្នកស្រី តេសសូណា ជាគណៈ-កម្មការនៅព្រះសហគមន៍កាតូលិកមេមត់បានប្រាប់ឲ្យដឹងថា "ក្នុងឆ្នាំនេះគឺយើងបានប្រមូលកុមារៗ មកពីបណ្តាភូមិផ្សេងៗ ទាំងកូនគ្រីស្ត-បរិស័ទ ទាំងមិនមែនជាគ្រីស្តបរិស័ទ ជាពិសេស កុមារក្រីក្រមួយចំនួន ដើម្បីឲ្យទទួលបានចំណេះដឹង អំពីអនាម័យព្រោះថា បច្ចុប្បន្នព្រះ-សហគមន៍ កំពុងយកចិត្តទុកដាក់ជំរុញឲ្យកុមារ មានកម្លាំងសម្រាប់ការសិក្សា និងយកចិត្តទុកដាក់ទាំងសុខភាព អនាម័យរបស់ពួកគេផងដែរ"។ អ្នកស្រីបន្តថា កម្មវិធីនេះក៏ចង់ឲ្យកុមារស្គាល់គ្នាទៅវិញទៅមក ទទួលបានអំណរសប្បាយ និងការលេងល្បែង បញ្ចេញនូវសមត្ថភាព ដែលពួកគេមានផងដែរ។ **ក**



*ព្រះសហគមន៍អបអរសាទថ្ងៃសិទ្ធិកុមារ*


ពាក្យប្រឡងរួចច្បាប់ តម្លៃ ៨០០០ រៀល

ចាប់ទទួលពាក្យប្រឡង 10-13 សីហា 2015

**មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈនិងបច្ចេកទេសដុនបូស្កូភ្នំពេញ**

**ត្រូវការជ្រើសរើសសិស្ស**

ការជ្រើសរើស :

បេក្ខជនចាំបាច់ត្រូវឆ្លងកាត់ការសម្ភាសន៍ ពីគណៈគ្រប់គ្រងសាលា និង ការប្រឡងវិញ្ញាសារចំនួន ៤ មុខវិជ្ជាគឺ៖

១. វប្បធម៌ទូទៅ ២. អង់គ្លេស
៣. គណិតវិទ្យា ៤. គំនូរល្បងប្រាជ្ញា

ទូរស័ព្ទ: 023 23 14 64 website : www.donboscokhmer.org

**កម្មវិធីបណ្តុះបណ្តាល**

ជំនាញវិជ្ជាជីវៈ: C1, C2, C3

សិក្សាក្នុងសាលា ១៧ខែនិង ចុះកម្មសិក្សាតាមរោងចក្រ សហគ្រាស៣ខែ។

ជំនាញ ៖ - បោះពុម្ព
- គ្រឿង -ផ្សារ -ជួសជុលរថយន្ត

បច្ចេកទេសជាន់ខ្ពស់(អនុវិស្វករ)

សិក្សាក្នុងសាលា ២០ខែ និងចុះកម្មសិក្សាតាមរោងចក្រ សហគ្រាស៣ខែ។

ជំនាញ ៖-គ្រឿង-ផ្សារ -ជួសជុលរថយន្ត
- អគ្គិសនី - អេឡិចត្រូនិច
- កុំព្យូទ័រ



បងស្រី អាង សង្វាត

## លើកតម្កើងព្រះកាយ និងព្រះលោហិតព្រះគ្រីស្ត

( មក ១៤,១២-១៦ និង ២២-២៦ )

នៅថ្ងៃព្រហស្បតិ៍ មុនព្រះយេស៊ូសោយទិវង្គត ព្រះអង្គបានធ្វើពិធីជប់លៀងជាមួយក្រុមសាវ័ក ទាំង១២នាក់។ ព្រះអង្គយកនំប៉័ង មកកាន់អរព្រះគុណព្រះជាម្ចាស់ ហើយបែងចែកនំប៉័ង និង ស្រាឲ្យក្រុមសាវ័កបរិភោគ។ ព្រះអង្គធ្វើដូច្នេះ ទុកជាសញ្ញាសំគាល់បង្ហាញឲ្យដឹងថា ព្រះអង្គសព្វព្រះហឫទ័យ បូជាព្រះជន្មដោយគ្មាននរណាបង្ខំឡើយ។

លោក លូកា ចង់បញ្ជាក់ពីអត្ថន័យនៃការរងទុក្ខលំបាក របស់ព្រះយេស៊ូ ដែលសុខចិត្តបូជាព្រះជន្មដើម្បីសង្គ្រោះមនុស្សលោក។ មានតែព្រះយេស៊ូមួយព្រះអង្គគត់ ដែលសព្វព្រះហឫទ័យ ទទួលទុក្ខលំបាកទាំងអស់ ដោយមានបំណងសម្តែងសេចក្តីស្រឡាញ់ ដ៏ហួសកម្រិតរបស់ព្រះអង្គចំពោះព្រះបិតា។ ព្រះអង្គស្រឡាញ់ ព្រះបិតាហួសពីការស្មានរបស់មនុស្ស និងស្រឡាញ់ព្រះបិតាក្នុងនាមមនុស្សទាំងអស់។

*( សូមធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ )*

ព្រះអង្គសុំឲ្យសាវ័ក រួមចិត្តគំនិតជាមួយព្រះអង្គ ដែលបូជាព្រះជន្ម ហើយព្រះអង្គ ក៏សុំយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទឲ្យស្ម័គ្រចិត្តថ្វាយកាយវាចាចិត្ត ដើម្បីបម្រើអ្នកដទៃ ដូចព្រះអង្គ គឺរហូតដល់បូជាជីវិតរបស់ខ្លួនដោយមិនគ្រាន់តែធ្វើបុណ្យដើម្បីនឹករំឭកតែប៉ុណ្ណោះ។

## អាទិត្យទី ១១ រដូវធម្មតា

( មក ៤,២៦-៣៤ ) ប្រស្នាអំពីគ្រាប់ពូជដុះ

- អត្ថបទដំណឹងល្អថ្ងៃនេះ លោកម៉ាកុស រ៉ាយរ៉ាប់ពីពាក្យប្រស្នា គឺរិទ្ធានុភាពរបស់ព្រះជាម្ចាស់ធ្វើ ឲ្យព្រះរាជ្យព្រះអង្គមកដល់បន្តិចម្តងៗ ។ មានតែព្រះជាម្ចាស់ ប៉ុណ្ណោះដែលធ្វើឲ្យគ្រាប់ពូជដុះឡើង និងបង្កើតផល។ កសិករជាអ្នកសាបព្រោះ មិនដឹងថា ( ស្រូវដែលគាត់សាបព្រោះដុះតាមរបៀបណាឡើយ ) ចំនុចនេះព្រះយេស៊ូ លើកទឹកចិត្តសាវ័ករបស់ព្រះអង្គកុំឲ្យអស់សង្ឃឹមទោះបីមិនឃើញលទ្ធផលភ្លាមៗនៃកិច្ចការរបស់ខ្លួនក្តី ក៏ព្រះរាជ្យនេះ នឹងមកដល់ជាមិនខាន។ ព្រះយេស៊ូបានសាបព្រោះព្រះបន្ទូល តែព្រះអង្គមិនបានឃើញផលភ្លាមៗទេ គឺត្រូវរង់ចាំយ៉ាងយូរទើបឃើញលទ្ធផល។ សព្វថ្ងៃព្រះសហគមន៍ហាក់ដូចជាកំពុងតែទទួលផលផ្លែដែរ គឺជាផលដែលបានមកពីការសាបព្រោះរបស់ព្រះជាម្ចាស់ តាមរយៈអស់លោកបុព្វបុរស ដែលបានលះបង់ជីវិត ក្នុងការប្រកាសដំណឹងល្អនៅសម័យមុនៗ។ រៀងរាល់ឆ្នាំមានបងប្អូន ជាច្រើនរយនាក់ទទួលអគ្គសញ្ញាជ្រមុជទឹក ដើម្បីចូលរួមជាមហាគ្រួសារក្នុងព្រះសហគមន៍។

## អាទិត្យ ទី១២ រដូវធម្មតា

( មក ៤, ៣៥-៤១ )

ព្រះយេស៊ូ ធ្វើឲ្យរលកស្ងប់

ដំណឹងល្អក្នុងសប្តាហ៍នេះ នាំឲ្យយើងនឹករលឹក ដល់បងប្អូនគ្រីស្តបរិស័ទក្រុងរ៉ូមសម័យដើម ដែលត្រូវរដ្ឋអំណាចបៀតបៀន ធ្វើបាបមើលងាយ កាប់សម្លាប់យ៉ាងព្រៃផ្សៃ និងអយុត្តិធម៌ដោយសារតែជំនឿ។ ហើយអត្ថបទនេះ ក៏ជួយយើងឲ្យរិះគិតពីព្រះសហគមន៍របស់យើង សព្វថ្ងៃនេះដែរ។

ពេលឆ្លងទូកទៅត្រើយម្ខាង គឺជារយៈពេលមួយ នៃការធ្វើដំណើរទៅកាន់សាសន៍ដទៃ ដែលសាវ័កត្រូវប្រឈមមុខជាមួយបញ្ហាផ្សេងៗតាមផ្លូវនៃការនាំដំណឹងល្អ ។

សព្វថ្ងៃគ្រីស្តបរិស័ទ ដែលជាអ្នកជឿលើព្រះយេស៊ូ ចេញទៅប្រកាសដំណឹងល្អ ហើយច្រើនដងយើងជួបឧបសគ្គ មានបញ្ហាផ្សេងៗជាច្រើន។ ពេលខ្លះ ជួបគ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ ពេលខ្លះត្រូវគេមើលងាយបៀតបៀន ពេលខ្លះមានការភ័យខ្លាច ឬ ធ្លាក់ទឹកចិត្ត អស់សង្ឃឹម និងពេលខ្លះទៀត នាំឲ្យយើងមានការសង្ស័យចំពោះវត្តមានរបស់ព្រះអង្គ (លោកគ្រូ យើងស្លាប់អីឡូវហើយ! លោកមិនអើពើទេឬ?) ពេលយើងជួបការលំបាក ពេលនោះ យើងតែងគិតថា ព្រះអង្គបោះបង់យើងចោល ព្រះអង្គភ្លេចយើង។

ហេតុអ្វី បានជាអ្នករាល់គ្នាភិតភ័យដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬ?

សព្វថ្ងៃ ព្រះសហគមន៍ ហាក់ដូចជាទូក ដែលកំពុងស្ថិតនៅលើផ្ទៃទឹកសមុទ្រដ៏ធំធេង។ ចំណែកសាវ័ក ដូចជាយើងទាំងអស់គ្នា ជាគ្រីស្តបរិស័ទដែលចេញទៅប្រកាស ដំណឹងល្អដល់អ្នកកាន់សាសនាដទៃ ឬបំពេញតួនាទីអ្វីមួយ ដើម្បីជួយព្រះសហគមន៍ យើងងាយមានការសង្ស័យ មានការភ័យខ្លាច និងចាញ់ការល្បួងផ្សេងៗ នៅពេលណាជួបឧបសគ្គ ឬបញ្ហាណាមួយ ដែលនាំឲ្យអស់សង្ឃឹមធ្លាក់ទឹកចិត្ត យើងតែងតែសួរថា ព្រះជាម្ចាស់នៅទីណា? ហេតុអ្វីពេលនេះព្រះអង្គមិនយាងមកជួយ... ព្រះអង្គបោះបង់យើងចោល? ហេតុអ្វីព្រះអង្គព្រងើយកន្តើយមិនរវីរវល់នឹងការលំបាករបស់យើងផង? ព្រះអង្គកំពុងដាស់តឿន និងរំឭកយើងតាមរយៈដំណឹងល្អរបស់លោកម៉ាកុស ទាំងសាវ័ករបស់ព្រះអង្គ ទាំងគ្រីស្តបរិស័ទសម័យមុន និងសម័យបច្ចុប្បន្ននេះថា យើងទាំងអស់គ្នាត្រូវមានចិត្តជឿនិងសង្ឃឹមជានិច្ច ទោះបីមានការលំបាកជួបឧបសគ្គទាំងឡាយ តាមផ្លូវនៃបេសកកម្ម។ សូមកុំភ័យខ្លាច កុំបោះបង់ជំនឿ ត្រូវជឿទុកចិត្តលើព្រះអម្ចាស់។ ព្រះអង្គគង់នៅជាមួយយើងជានិច្ច ត្រូវតែបន្តបេសកកម្មនេះដោយមិន ត្រូវរាថយឡើយ។ មានតែព្រះយេស៊ូប៉ុណ្ណោះ ដែលអាចធ្វើឲ្យខ្យល់ព្យុះនិងសមុទ្រស្ងប់ មានតែព្រះអង្គប៉ុណ្ណោះ ដែលអាចធ្វើឲ្យយើងមានកម្លាំង ឈ្នះមារ ឈ្នះរាល់ការល្បួងទាំងឡាយបាន។ យើងត្រូវតែមានទំនាក់ទំនង ជាមួយព្រះអង្គជានិច្ច ក្នុងគ្រប់កិច្ចការទាំងអស់ ព្រះអង្គមានព្រះជន្មជានិច្ច ក្នុងគ្រប់កាលៈទេសៈ នៃដំណើរជីវិតរបស់អ្នកជឿសង្ឃឹមលើព្រះអង្គ។

## អាទិត្យទី ១៣ ក្នុងរដូវធម្មតា

( មក ៥,២១-៤៣ )

*ព្រះយេស៊ូ បានប្រោសស្ត្រីមានជម្ងឺធ្លាក់ឈាមម្នាក់ឲ្យជា*

- ដំណឹងល្អអាទិត្យនេះ តាមលោកម៉ាកុស ព្រះយេស៊ូបានសម្តែងឫទ្ធិបារមី២យ៉ាងគឺ ទី១ព្រះអង្គប្រោសស្ត្រីមានជម្ងឺធ្លាក់ឈាមឲ្យបានជា និងទី២ប្រោសកូនស្រីរបស់លោកយ៉ៃរ៉ូសឲ្យរស់ឡើងវិញ។

ស្ត្រីម្នាក់ ដែលមានជម្ងឺធ្លាក់ឈាមជាយូរណាស់មកហើយ "ហើយគ្មានគ្រូពេទ្យណា អាចជួយព្យាបាលនាងបានឡើយ គ្រាន់តែពាល់ជាមួយព្រះហស្ថរបស់ព្រះអង្គ នាងក៏បានជាសះស្បើយមួយរំពេច។ ព្រះយេស៊ូចង់ពន្យល់ប្រាប់សាវ័ក ឲ្យយល់ពីកាយវិការរបស់នាង ដែលពោរពេញដោយជំនឿ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យនាងមានទំនាក់ទំនងផ្ទាល់ ជាមួយព្រះអង្គ និងឲ្យនាងបានទទួលការសង្គ្រោះ។ នាងមានបំណងចង់ឲ្យបានជាសះស្បើយ តែពេលដែលបានជួបព្រះយេស៊ូ ព្រះអង្គប្រទានឲ្យនាងបានទទួលហួសពីអ្វីដែលនាងប្រាថ្នា។ ព្រះយេស៊ូមានព្រះបន្ទូលថា (កូនស្រីអើយ ជំនឿនាងបានសង្គ្រោះនាងហើយ) ការសង្គ្រោះ មានអត្ថន័យជ្រៅជាង ការជាសះស្បើយ ។

ចំណែកលោក យ៉ៃរ៉ូសវិញ មុនដំបូង លោកជឿនិងសង្ឃឹមថា មានតែព្រះយេស៊ូប៉ុណ្ណោះ ដែលជួយឲ្យកូនស្រីរបស់លោក បានជាសះស្បើយពីជម្ងឺ។ ពេលមានគេប្រាប់ថា (កូនរបស់លោកស្លាប់ហើយ!) គាត់នៅស្ងៀម ហាក់ដូចជាគាត់នៅតែមានជំនឿលើព្រះយេស៊ូដដែល។ ព្រះយេស៊ូ បានលើកទឹកចិត្តគាត់ ដោយមានព្រះបន្ទូលថា (កុំខ្លាចអ្វី! គ្រាន់តែជឿប៉ុណ្ណោះ ! )

លោក ម៉ាកុស បានយករឿងស្ត្រីធ្លាក់ឈាម មកជ្រៀតចូលក្នុងរឿងកូនស្រីលោកយ៉ៃរ៉ូសដែលស្លាប់ ដើម្បីពន្យល់ជំនឿលើរិទ្ធានុភាព របស់ព្រះយេស៊ូ ។

សព្វថ្ងៃ យើងជាគ្រីស្តបរិស័ទ មានជំនឿលើព្រះយេស៊ូបែបណាដែរ? តើយើងចង់បានអ្វីពីព្រះអង្គ? ចំពោះខ្លួនខ្ញុំផ្ទាល់ តើការសង្គ្រោះមានអត្ថន័យយ៉ាងណាដែរ? តើការសង្គ្រោះនេះផ្តល់ឲ្យខ្ញុំមានសេចក្តីសុខបែបណា ?

# រូបថតសកម្មភាពព្រះសហគមន៍ទាំងបីភូមិភាគ

## រូបភាពសកម្មភាពផ្សេងៗពីភូមិភាគភ្នំពេញ



បុណ្យព្រះនាងម៉ារីជាទីពំនឹងពំនាក់នៅដុនបូស្កូ។




ក្រុមលោកអភិបាលកម្ពុជា-ឡាវ(CELAC)។



សម្ពោធហាង Peace Caffe នៅភ្នំពេញថ្មី។



បេក្ខជនទទួលអគ្គសញ្ញាលាបថ្ងាសពីលោកអភិបាល អូលីវីយេនៅទីក្រុងសៀងហៃប្រទេសចិន។



អគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍ពោធិ៍ធំ។



អគ្គសញ្ញាលាបថ្ងាសនៅព្រះសហគមន៍សន្តយ៉ូសែប (ផ្សារតូច)។

## រូបភាពសកម្មភាពផ្សេងៗពីភូមិភាគកំពង់ចាម




សិក្ខាសាលាព្រះគម្ពីរ
នៅព្រះសហគមន៍កាតូលិកអ្នកលឿង។



ទិវាសិទ្ធិកុមារអន្តរជាតិ
នៅព្រះសហគមន៍អ្នកលឿង។



ទិវាសិទ្ធិកុមារអន្តរជាតិ
នៅព្រះសហគមន៍កំពង់ចាម។

## រូបភាពសកម្មភាពផ្សេងៗពីភូមិភាគបាត់ដំបង





បុណ្យរំលឹកមរណសាក្សី លោកអភិបាល ទេពអ៊ីម សុត្ថា នៅស្វាយស៊ីសុផុន។



សិក្ខាសាលាព្រះគម្ពីរជាមូលដ្ឋាននៅព្រះសហគមន៍បាត់ដំបង។

អេម៉ាញូអែល
"សម្លេងពីព្រះសហគមន៍កាតូលិក"

| | |
|---|---|
| ភ្នំពេញ | : **FM 104 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| បាត់ដំបង | : **FM 91.0 Mhz** ម៉ោង ៧:៣០- ៨:៣០ រាល់ថ្ងៃ |
| សៀមរាប | : **FM 107.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ធំ | : **FM 103.5 Mhz** ម៉ោង ៧:០០- ៨:០០យប់ រាល់ថ្ងៃ |
| កំពង់ចាម | : **FM 100.5 Mhz** ម៉ោង ៧:០០- ៨:០០ រាល់ថ្ងៃ |
| ព្រះសីហនុ | : **FM 92.5 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |
| កំពត | : **FM 93.25 Mhz** ម៉ោង ៥:០០- ៦:០០ រាល់ថ្ងៃ |

**កម្មវិធីវិទ្យុ**

**"ខ្ញុំត្រូវការអ្នក"**

**ជាកម្មវិធីសម្រាប់យុវជន**

ផ្សាយតាមរលកធាតុអាកាស FM99.5Mhz
រាល់ថ្ងៃអង្គារ៍
វេលាម៉ោង ១០:០០ - ១១:០០ព្រឹក